«សុភាពបុរសក្នុងត្រកូលអភិជន ប៉ែន ពេជ្រប្រាថ្នា »

.....ប៉ែន ពេជ្រប្រាថ្នា កូនប្រុសច្បងរបស់ឧកញ៉ា ប៉ែន ពេជ្រ។
ក្នុងវ័យ៣២ឆ្នាំគឺជាអគ្គនាយកសាជីវកម្មអចលនទ្រព្យ K.I.C ដែលមានទុន១៨លានដុល្លារអាមេរិកលើទីផ្សារ។ ក្នុងនាមជាបុត្រាទោលនិងជាបុត្រច្បងនៃភរិយាដើមរបស់ឧកញ៉ា ប៉ែន ពេជ្រ គឺលោកជំទាវ សក្ខកុសុមា លោក ប៉ែន ពេជ្រប្រាថ្នា គឺជាយុវជនដ៏មានកេរ្តិ៍ឈ្មោះនិងជាទីចោមរោមនៃបុប្ផាស៊ីវិល័យជិត ឆ្ងាយ។




«បាទលោកអ៊ំ! ក្មេងៗវាភ្លាត់ ហើយអាបរទេសហ្នឹងត្រូវដៃជើងរបស់យុត្តនាចាប់បាន! ខ្ញុំក៏មិនយល់ដែរថាហេតុអ្វីបានជាយុត្តនាគេធ្វើអញ្ចឹងបានជា ខ្ញុំខលទៅជម្រាបសួរសុំយោបល់ពីលោកអ៊ំ!»គេនិយាយដោយសព្ទសំឡេង រាបសាតែភាពមួហ្មងលាក់បាំងក្នុងពន្លឺភ្នែកមិនឲ្យគូសន្ទនាដឹង ឡើយ។
អ្នកដែលកំពុងនិយាយឆ្លើយឆ្លងទូរសព្ទជាមួយគេ ទំនងជាបុគ្គលមានឥទ្ធិពលដែលគេចាំបាច់

ត្រូវតែគ្រប់គ្រងអារម្មណ៍របស់ ខ្លួន។ សំឡេងបុរសចំណាស់នោះនិយាយតបមកវិញ៖
«ស្ងប់ចិត្តសិន! ចាំអ៊ំសួរនាំយុត្តនាឲ្យ! ប្រហែលគេមិនដឹងថានេះជាគម្រោងការរបស់អ៊ំដែលឲ្យគំនិតក្មួយធ្វើ បានជាគេមកលូកដៃ!»
«លោកអ៊ំជ្រាបស្រាប់ហើយថា យុត្តនាពីដើមមកមានគំនុំជាមួយលោកប៉ា! គេគ្មានហេតុផលអីទៅជួយលោកប៉ាទេក្នុងកាលៈទេសៈនេះ ខ្ញុំឆ្ងល់ដែរថាហេតុអ្វីបានជាគេបែរជាចាប់ចូហាន់មក!? »
«គេប្រហែលជាមានបំណងសួររកអ្នកនៅពីក្រោយរឿងបោកប្រាស់១១លាន ដុល្លារនេះហើយ ពេលដឹងថាជាក្មួយដែលលេងឪពុកខ្លួនឯង គេកាន់តែសប្បាយចិត្តព្រោះព្រួញមួយបាញ់បានសត្វពីរគឺ ធ្វើឲ្យក្មួយឯងជាប់ទោស ទីពីរ ធ្វើឲ្យប៉ាក្មួយឯងឈឺចិត្ត»
សំឡេងនោះពន្យល់មកវិញធ្វើឲ្យនាយប្រាថ្នាបើកភ្នែកធំៗ។ គេនិយាយទាំងហើបគូទពីកៅអី៖
«អញ្ចឹងបើយុត្តនាប្រគល់នាយចូហាន់ទៅឲ្យប៉ូលិស វានោះសារភាព...ខ្ញុំមិនចប់ជាមួយលោកប៉ាទៅ ហើយ? លោកអ៊ំជ្រាបដែរ ខ្ញុំធ្វើអញ្ចឹងគ្រាន់តែចង់ឲ្យលោកប៉ាទ័លច្រកហើយបកមករកជំទាវ ម៉ាក់វិញ ខ្ញុំគ្មានបំណងអាក្រក់អីទេ!»
បុរសចំណាស់ដែលជាគូសន្ទនាសើចស្រាលៗតបនឹងភាពតក្កមារបស់ ប៉ែន ពេជ្រប្រាថ្នា។ គាត់និយាយក្នុងភាពអំណត់៖
«ល្អហើយដែលខលមកប្រាប់! ចាំអ៊ំចាត់ការខាងយុត្តនាឲ្យ!»
ប្រាថ្នាអរព្រើត គេហៀបនឹងថ្លែងពាក្យអរគុណស្រាប់ប្រដាប់បញ្ជូនសំឡេងលើតុឲ្យសញ្ញា គេលូកដៃចុចទទួល ហើយសំឡេងនាងលេខាលាន់មកស្រួយស្រែស៖
«លោកអគ្គនាយក អ្នកនាង ពៅបញ្ញាសុំជួបទាន!»
ប្រាថ្នាបង្ហាញភាពទោមនស្សក្នុងក្រសែភ្នែក គេនិយាយកំបុត៖
«ឲ្យចាំសិនទៅ!»
រួចចុចបិទឧបករណ៍នោះ។ គេងាកមករអ៊ូដាក់គូសន្ទនា៖
«ថាមែនៗ! ស្រីឆ្នាសនោះមករកដល់ក្រុមហ៊ុនខ្ញុំហើយលោកអ៊ំ! ច្បាស់ជានិយាយរឿងហ្នឹងហើយ!»
«ចុះម៉េចក៏ដឹងលឿនម្ល៉េះ?»
«អ្នកតាមដានរបស់ខ្ញុំឃើញយុត្តនាហៅប្អូនខ្ញុំទៅជួបនៅ Apartment បឹងកេងកង! តាមមើល

យុត្តនានិយាយប្រាប់ អស់ហើយ!»
«កូនយុត្តនាស្អប់គ្រួសារនោះណាស់! បើថាប្រាប់ក៏មិនមែនប្រាប់ក្នុងបំណងល្អដែរ !»

ប៉ែន ពេជ្រប្រាថ្នា ក្តៅចិត្តឆេវះ៖
«កូនធម៌អុំនេះ ចរិតពេលខ្លះពិបាកយល់ពិបាកអត់ធ្មត់មែនហ្មង! ខ្ញុំយល់ អុំទេណា!»
«ទប់ចិត្តសិនទៅ! ចាំអុំនិយាយឲ្យ! ប៉ុណ្ណឹងចុះ! ទទួលប្អូនស្រីពៅសិនទៅ!»
«បាទ! ក្មួយសុំជម្រាបលា!»
គេទម្លាក់ទូរសព្ទចុះជាមួយក្រសែភ្នែកមានកលដែលដៀងទៅរកមាត់ទ្វារបន្ទប់។
ម្រាមដៃខាងស្តាំលូកទៅចុចឧបករណ៍បញ្ជូនសំឡេងហើយនិយាយកំបុតដដែល៖
«ឲ្យពៅបញ្ញាចូលមក!»
«ចាំលោក!»

សំឡេងនារីលេខារលត់បាត់ ស្នូរគោះទ្វារលាន់មកនៅមួយខណៈក្រោយ។
«អញ្ជើញ!» គេនិយាយតិចៗដោយធ្វើជាឈ្ងោករវល់ជាមួយសំណុំឯកសារពីមុខខ្លួន។
ខ្សែភ្នែកដំបូងរបស់គេគឺឃើញស្បែកជើងកែងរបស់នាងគេប្រឹងញញឹមធ្វើដូចសុភាពបុរស
ហើយងើបមុខវឹង៖
«ខ្យល់អីបក់ប្អូនស្រីពៅមកលេង ដល់ទីនេះ?»
ពៅបញ្ញាកាន់តែមិនសប្បាយចិត្តចំពោះការធ្វើពើរបស់បុរសជាបង ម្តាយទីទៃ។ តែនាងគឺជា
នារីមិនដែលព្រមចុះចាញ់អ្វីងាយៗស្រាប់ហើយ។ ស្រីឈានចូលមកដោយទឹកមុខញញឹម
តិចតួចអមជាមួយភាពស្រងូតក្នុងពន្លឺ ភ្នែក។ ប្រាថ្នាក្រោកមកទាញកៅអីទទួលប្អូនស្រីដោយ
អាកប្បកិរិយាដ៏សុភាពនៃ យុវជនសម័យទំនើប។
«អង្គុយម៉ោ! ហើយញ៉ាំកាហ្វេឬតែ?»
ពៅបញ្ញាជាមនុស្សទៀងត្រង់គ្មានល្បិចកលតាំងពីដើមមក។ នាងក៏មិនចង់បង្វែងរឿងវែង
ឆ្ងាយដែរ ស្រីកម្សត់និយាយតបមួយៗ៖
« ខ្ញុំមក....ព្រោះតែរឿងល្ខោនលុយ១១លាននោះ!»
អភិជនវ័យក្មេងទច់ចលនាបន្តិចហើយថ្លោះទឹកមុខ ព្រោះគេមិននឹកថានាងចូលដល់ប្រធាន
បទលឿនយ៉ាងនេះ។

គេថយទៅអង្គុយនៅកន្លែងដើមក្រោមក្រសែភ្នែកសម្លឹងគ្មានព្រិច របស់ពៅបញ្ញា។ នាងសម្លឹងគេមុតដល់ថ្នាក់ថាប្រាថ្នាដែលមានខ្លួនស្រាប់នោះហាក់ ព្រឺខ្នងបន្តិចដែរ តែគេបង្វែរសាច់រឿងធ្វើទឹកមុខស្រងូត៖

«លោកប៉ាមានរឿងបង ដឹងតើ! បងថាបង្ហើយការងារបន្ទាន់មួយចំនួនយនេះហើយ ទៅផ្ទះនោះពិភាក្សានិ ឹងងលោកប៉ា ទេសកាលអីប្អូនក៏មកដល់ល្មមបញ្ញា!»

«បើអញ្ចឹងទាន់ខ្ញុំនៅនេះស្រាប់ បងប្រាថ្នាយកលុយនោះចេញមកនឹងអាលបានខ្ញុំយកទៅទូទាត់ឲ្យភាគហ៊ុនទាំងនោះវិញ!!»

ប្រាថ្នាលើកចិញ្ចើមធ្វើពើដោយទឹកមុខស្លូតបូត៖

«តែ...មកយកភ្លាមៗបងទៅរកឯណាមកទាន់ លុយលានណ៎ា ជាង១០លាន! បងចង់ជួយតែឲ្យប៉ាទៅរកជំទាវម៉ាក់ទៅ លោកស្គាល់គេច្រើនក្រែងមានមធ្យោបាយរកទាន់ពេល! ត្បិតតែលោកប៉ាបានភរិយាថ្មីចោលប្រពន្ធកូនចោលជំទាវម៉ាក់ លែងគ្នាដាច់តាមផ្លូវច្បាប់តែមនោសញ្ចេតនាប្រាកដជាមាន បងនឹងជួយនិយាយ!»

ពៅបញ្ញាតឹងតែងចិត្តណាស់ចំពោះកាយវិការក្លែងបញ្ឆោតទាំងនេះ។ ដោយហេតុតែពេលវេលាកាន់តែកៀក ទុក្ខសោកចោមរោមច្រើនហួសដល់ថ្នាក់នាងមួហ្មងមិនចង់ទ្រាំមើលល្ខោននេះតទៅទៀត ស្រីតូចក៏តវ៉ាតបតវិញដោយទឹកមុខនឹងនះ៖

«បងប្រាថ្នា ឈប់សម្តែងទៅ! ពេលនេះខ្ញុំមិនសុំជំនួយទេ គ្រាន់តែសុំបងប្រគល់លុយដែល Mr. Johan បោកនោះមកវិញ! លោកប៉ានៅឈឺ បងយោគយល់ផង!»

ប្រាថ្នាប្រកែកញ៉ាញធ្វើដូចមិនដឹងរឿង៖

«Mr. Johan? ហើយគេយកលុយលោកប៉ាទៅមានទាក់ទងអីនឹងបង?»

ពៅបញ្ញាសើចស្ងួត នាងនិយាយដោយសម្លឹងគេមិនព្រិច៖

«ខ្ញុំដឹង! ថាបងនៅពីក្រោយរឿងនេះ! Mr. Johan ទទួលបាន១លានប៉ុណ្ណោះទេ! ខ្ញុំមិនដេញដោលអីក៏បាន តែបងត្រូវសងលុយមកវិញមុនរឿងធំជាងនេះ!!»

«ពៅបញ្ញា? ឯងយកស្អីមកនិយាយ? បងមិនដែលស្គាល់អាម្នាក់ណាឈ្មោះ Johanទេ!»

ពៅបញ្ញានិយាយតិចៗតែសង្កត់ពាក្យ៖

«ហួត យុត្តនាចាប់បានគេនោះហើយបងធ្វើពើអត់ប្រយោជន៍ទេ! គេសារភាពរឿងបងអស់ហើយ!»

ប្រាថ្នាទម្លាក់ទឹកមុខ គេធ្វើសោះអង្គើយ ព្រោះចាប់ផ្ដើមមួម៉ៅកាលបើឮឈ្មោះនាយយុត្តនា ដែលបានក្លាយជាឆ្អឹង ទទឹងកនៃគម្រោងការរបស់គេ។ គេនិយាយដោយសម្លឹងទៅទីផ្សេង៖
«អាម្នាក់ហ្នឹងវាមិនចូលចិត្តលោកប៉ា! វាស្អប់គ្រួសារយើង វាគិតថាលោកប៉ាបានធ្វើឲ្យប៉ាវាស្លាប់!ឥឡូវនេះវានិយាយប៉ុន្មាន ម៉ាត់ អូនឯងក៏ជឿស៊ុបហើយមកស្ដីថាឲ្យបង? គួរតែឯងនឹកគោរពបងខ្លះពៅបញ្ញា? បងមិនដែលគិតស្អីទៅធ្វើបាបឪពុកខ្លួនឯងទេ!»
ពៅបញ្ញាដឹងថាចំណាយពេលក៏គ្មានប្រយោជន៍នាងនិយាយដាច់ណាត់៖
«បើបងមិនព្រមចូលសាច់រឿង ខ្ញុំនឹងទៅយក Mr. Johan ហ្នឹងពីលោកយុត្តនាទៅប្រគល់ឲ្យប៉ូលិស! បងនិយាយកុហកឬគេម្នាក់នោះនិយាយកុហក ប៉ូលិសគង់តែរកឃើញការពិតទេ!»

នាងសម្លឹងមុខគេហើយខាំបបូរមាត់តិចៗព្រោះឈឺចិត្តដែលគេមានឈាម ដូចនាង បែរជាមិនចេះគិត អាចធ្វើសូម្បីតែរឿងបង្ខូចឈ្មោះឪពុកខ្លួន។
ធុរកិច្ចជនវ័យក្មេងគេសម្លឹងនាងវិញដោយទឹកមុខរាវែក ដូច្នេះមាណវីក៏ក្រោកដើរចេញរឹងធ្វើឲ្យនាយប្រាថ្នាត្រូវតែបង្ខំ ចិត្តហៅនាងតិចៗ៖
«ពៅបញ្ញា!»
នាងបញ្ឈប់ជើងហើយបែរក្រោយយឺតៗ ….
ប៉ែន ពេជ្រប្រាថ្នា ក្រោកពីកៅអី ទាញតម្រង់ក្រវាត់កតិចតួចហើយគ្រហែមយកសំឡេងនិយាយបន្ត៖
«បានៗៗ អ្នកច្បាប់អើយ!! បងចាញ់ឯងៗ! កុំឲ្យអ្នកណានិយាយរឿងនេះបានអត់?លុយបង្វិលទៅវិញល្ងាចនេះតាមដែលបងអាចធ្វើបានរហ័សប៉ុណ្ណា! តែឯងត្រូវសន្យានឹងបង ធ្វើគ្រប់យ៉ាងបិទមាត់អាយុត្តនានោះ!»
ស្រីតូចអរព្រើតនិមិត្តតែឮថាបានប្រាក់មកវិញ។ តែឃើញមុខងើលរបស់បងប្រុសដែលមិនចេះគិតនាងមិនអាចនៅស្ងៀមមិន និយាយបានទេ៖
«នៅមិននៅទៅធ្វើរឿងល្មើសច្បាប់ បើលេចឮចេញទៅវាមិនត្រឹមតែខូចឈ្មោះវង្សត្រកូលទេថែមទាំងជាប់ពិរុទ្ធទទេខូចដំណើរការរកស៊ីទៀត! ខ្ញុំកោតណាស់ដែលបងធ្វើទៅរួច! នាំអ្នកក្រៅមកប្លន់អ្នកមានគុណខ្លួនឯង! »
ទោះយ៉ាងណាសុភាពបុរសក្លែងក្លាយគឺជាអ្នកដឹងចិត្តប្អូនស្រីចុងម្នាក់នេះជាងគេ។ គេដឹងថានាងចិត្តរឹងប៉ុណ្ណាក៏មិនដល់ថ្នាក់ដាច់ចិត្តឲ្យខ្លួន ជាប់គុកដែរ ព្រោះវាអាចធ្វើឲ្យមាន

រឿងធំប៉ះពាល់ដល់ឈ្មោះនិងសុខភាពផ្លូវចិត្ត ឪពុក។ គេនិយាយលួងវិញដោយទឹកមុខស្រពោនៈ
«ឯងស្មានថាបងចង់? លុយប៉ុណ្ណឹងស្មានតែជំទាវម៉ាក់គ្មាន? គឺបងអាណិតជំទាវម៉ាក់ ម៉ែ្ញៗនឹកតែលោកប៉ា តែអ្នកមីងម្ដាយឯងស្លាប់ទៅច្រើនឆ្នាំហើយលោកប៉ាក៏នៅតែមិនវិល មករស់នៅផ្ទះធំវិញសោះ! គឺបងជាអ្នកឃើញទឹកភ្នែកម្ដាយហូររាល់ថ្ងៃ! បងទ្រាំមិនបាន បងមានតែធ្វើឲ្យលោកប៉ាទាល់ ច្រកហើយគាត់វិលមករកអ្នកម៉ាក់វិញ!»
ពៅបញ្ញាហួសចិត្ត នាងសម្លឹងគេភ្លែ ធ្វើឲ្យបុរសជាបងខ្លាចពន្លឺភ្នែកនាង គេគេចចេញលែងហ៊ានសម្លឹងនាងចំ។

ពៅបញ្ញានិយាយផ្ទាន់គេៈ
«ចុះបើលោកប៉ាជ្រាប? គិតថាលោកលើកលែងឲ្យបងទេ? គិតថាលោកទទួលបានទេ!?»
ប្រាថ្នាលើកទឹកផឹកក្អឹកបំបាត់ភាពបារម្ភតែគំនិតនិយាយបន្លប់និង បំភ័ន្តភ្នែកនៅតែហូរចេញមកយ៉ាងល្អតាមរយៈសំឡេងស្ងួតរបស់គេៈ
«ដើម្បីម្ដាយ! កូនប្រុសច្បងម្នាក់អាចធ្វើអ្វីក៏បាន! រួមទាំងអារឿងជាប់គុកច្រវាក់នេះផងដែរពៅបញ្ញា!តែបងធ្វើនេះមិន បានឲ្យជំទាវម៉ាក់ជ្រាបទេ! គឺបងមានចេតនាឲ្យលោកត្រូវគ្នាវិញ! ឯងស្មានថាឯងអាចនៅជាមួយលោកប៉ាបានមួយជីវិត? ច្រើនណាស់ប៉ុន្មានឆ្នាំទៀតហ្នឹងឯងរៀបការចោលលោកហើយ! ចុះបើឲ្យលោកទាំងពីរជុំគ្នាវិញវាមិនល្អទេ? បងអង្វរឯងកុំឲ្យលោកប៉ាឬអ្នកណាដឹង មិនមែនបងខ្លាចបាត់បង់មុខមាត់ស្អីទេ! តែបងខ្លាចលោកប៉ាឈឺចិត្តនិងយល់ខុស! ទោះបីច្រើនឆ្នាំមកនេះបងប្អូនយើងបីនាក់ជាកូនប្រពន្ធដើម ត្រូវប៉ាបំភ្លេចចោលឲ្យនៅតែលតោលកំព្រា តែយើងទាំងពីររួមទាំងជំទាវម៉ាក់តែងតែសង្ឃឹមជានិច្ចថា ថ្ងៃណាមួយលោកប៉ានឹងវិលមកវិញ មកផ្ដល់ភាពកក់ក្ដៅឲ្យពួកយើងដូចមុន...»

គេបញ្ឈប់ប្រយោគកណ្ដាលទីទាំងដង្ហក់ណែនទ្រូងហាក់តូចចិត្តហួស ធ្វើឲ្យពៅបញ្ញាស្រពន់អស់កំហឹងទាំងប៉ុន្មាន ហើយងាកមុខគេចចេញពីបងប្រុសនាងវិញម្ដង។
ក្នុងនាមជាកូនទោលនៃភរិយាទីពីរ ត្បិតតែពៅបញ្ញាធំដឹងក្ដីមកដោយគ្មានបងប្អូនមួយគ្រាប់នឹងគេ តែនាងពិតជាមានឪពុកនិងម្ដាយនៅផ្ដល់ភាពថ្នាក់ថ្នមគ្រប់ពេលវេលា។
ការគាស់រំលឹកឡើងវិញនូវប្រវត្តិបែកខ្ញែកក្នុងគ្រួសារធ្វើឲ្យនាង ទទួលអារម្មណ៍ថាខ្លួនជាភាគីកូនចុងដែលមានកំហុសបំបែកឪពុកម្ដាយ គេនិងធ្វើឲ្យបងៗទាំងបីនៃភរិយាដើមបាត់បង់សុភ

មង្គលនិងភាព កក់ក្ដៅ។
ឃើញនាងធ្លាក់ក្នុងសិល្បវិធីរបស់ខ្លួន ហើយប្រាថ្នានិយាយបន្ត៖
«មានតែវាម្នាក់គត់ដែលដឹងរឿងនេះ! ដើម្បីគ្រួសារយើង! ឯងធ្វើយ៉ាងណាក៏បានគឺរកវិធីឲ្យវាបិទមាត់ចំណែករឿង Johanបងនឹងចាត់ការ»
ពៅបញ្ញាបើកភ្នែកមូលក្លុំសម្លឹងនាយសាជាថ្មី៖
«បងកុំធ្វើរឿងខុសច្បាប់ទៀតឲ្យសោះ!»
«មានឯណា! បងឲ្យអាJohanវាចេញផុតពីស្រុកខ្មែរទេ! »

....ភាពស្មុគស្មាញនិងស្រងូតលេចឡើងលើផ្ទៃមុខមេធាវីវ័យក្មេង។ តាមពិតដែលនាងពិបាកចិត្តមិនមែនរឿងលោកចូហាន់ទេ ព្រោះគេគ្មានថ្ងៃទៅសារភាពប្រាប់ប៉ូលិសឡើយនាំតែជាប់ជុចខ្លួន ឯង។ ដែលពិបាកចិត្តគឺរឿងបុរសម្នាក់.....ដែលនាងទើបតែឡើងទៅជួបគេកាលពីយប់មិញ។
«បើគេស្អប់ពួកយើងយ៉ាងនេះតើគេនឹងអាចជួយលាក់យើងដល់ពេលណាទៅ?» នាងគិតម្នាក់ឯងស្ងាត់ៗហើយដើរចាកចេញលែងមាត់តបនឹងបងប្រុសដែលលួច ញញឹមដោយកលពីក្រោយខ្នង។

## ៥

«អគ្គទេសាភិបាល ហួត ស៊ីវ»

.....អគ្គទេសាភិបាល ហួត ស៊ីវ ជាបុគ្គលល្បីឈ្មោះនិងមានគេឲ្យតម្លៃកោតគោរពជាទូទៅនៅក្នុងសង្គម ធុរកិច្ចជន។ បុរសខ្មែរកាត់ចិន វ័យ៥0ប្លាយនេះមិនដែលមានប្រវត្តិរៀបការ តែគាត់មានកូនប្រុសធម៌ម្នាក់ពីរដែរ។ កូនៗនោះបានត្រូវទំនុកបម្រុងស្ងាត់ៗតាំងពីតូចរហូតដល់ពេញវ័យអាច ជំនួសដៃជើងបាននូវធុរកិច្ចជាច្រើន។
ពាក្យចាស់ពោលថា «ដូងមានតក់មាននាឡិ» ថ្ងៃនេះប្រហែលជាមានកូនប្រុសណាម្នាក់ធ្វើឲ្យលោកខឹងហើយបានជា លេខាផ្ទាល់ខ្លួន គឺលោក ប៉េង ភិតភ័យរញ៉ីរញ៉ូវដើរទៅបើកទ្វារម្នាក់នោះឲ្យចូលមកជួបលោក អគ្គទេសាភិបាលដែលអង្គុយដោយទឹកមុខសៅហ្មងនៅលើកៅអីធ្វើការ។
«លោកប៉ានៅក្នុង?»

តាមពិតម្ចាស់សំណួរគឺបុរសសម្ដីចោលដឹងទាំងដងឈ្មោះយុត្តនាសោះ។ គេសួរនូវសំណួរនេះទាំងដឹងមុនស្រេចថា កាលដែលលោកប៉ាធម៌ហៅមកជួបទាន់ហន់គ្មានអ្វីក្រៅតែស្ដីបន្ទោសរឿង ដែលគេលូកដៃជួយពៅបញ្ញាចាប់នាយJohanនោះទេ។
«បាទ! លោកអគ្គចាំយូរហើយ!» លេខា ប៉េងនិយាយដោយទឹកមុខភិតភ័យ។
ទឹកមុខគាត់ធ្វើឲ្យយុត្តនាដឹងពីអ្វីដែលបម្រុងនឹងកើតឡើង តែគេនៅតែធ្វើពើជាមិនដឹងហើយហួចយ៉ាងគ្រលួចដាក់លេខាវ័យចំណាស់ រូបនេះ មុនពេលឈានឆ្ពោះទៅកាន់ទ្វារទីពីរដែលលោកប៉ាធម៌ដ៏មានអំណាចនៅ រង់ចាំជាស្រេច។

តុៗៗ....
«ចូលមក!» សំឡេងអគ្គទេសាភិបាលនៅតែស្ងួតទៅតាមទឹកមុខសោះអង្គើយរបស់គាត់ ប៉ុន្តែមិនមានបង្កប់ភាពសន្ធាប់ដោយកំហឹងនៅក្នុងនោះឡើយ។
យុត្តនាលើកដៃរៀបរយសក់ក្បាលហើយឈានចូលយឺតៗជាមួយស្នាមសើចបញ្ចេញស្នាមខួចក្នុងពេលតែមួយ៖
«លោកប៉ាអញ្ជើញមក Office ព្រលឹមដល់ហើយ!»
«អង្គុយមកកូន!» គាត់និយាយមួយៗទាំងលើកពែងកាហ្វេមកក្រេប។
យុត្តនាសម្លឹងទៅពែងកាហ្វេដែលមនុស្សជំនិតរបស់លោកប៉ាគេបាន ដាក់មកជូនគេ ក្នុងពេលនោះដែរជាតិកាហ្វេអេហ្សីបពិតជាឈ្ងុយ ធ្វើអោយគេនឹកឃើញថា ខ្លួនខានទៅកាហ្វេនៅផ្ទះជិតមួយខែមកហើយ។
នាយលើកពែងនោះមកក្រេបតែកន្ទុយភ្នែកដៀងទៅឃើញលោកលេខា ប៉េង វ័យចំណាស់នោះថយទៅឈរនៅពីក្រោយឪពុកធម៌ខ្លួនដូចសសរគ្មាន វិញ្ញាណ។
«តាប៉ិនេះហើយជាអ្នករាយការណ៍ចំណាប់» គេគិតស្ងាត់ៗម្នាក់ឯង។
សំឡេងអគ្គទេសាភិបាល ហួត ស៊ីវ លាន់មកកាត់ផ្ដាច់អារម្មណ៍ប៉ាចរហាចរបស់នាយ៖
«កូនឯងមួយរយៈនេះទំនេរដើរលេងអត់ចូលផ្ទះ នៅមិននៅទៅលូកដៃអីរឿងផ្ទះ ប៉ែន ពេជ្រនោះ?»
គេដាក់ពែងកាហ្វេចុះសន្សឹមៗហើយបង្វើបត្របកភ្នែករេទៅរកលេខា ប៉េង។ យុត្តនាឃើញបុរសនោះនៅឈរត្រង់ខ្លួនហើយឈ្ងោកមុខសឹងថាមិនហ៊ានដក ដង្ហើមផង។ យល់ចិត្តនាយលោកប៉ាធម៌បន្ថែមមកទៀតភ្លាម៖

«មិនមែនពូឯងមកប្រាប់ទេ គឺប្រាថ្នាគេខលមកនិយាយនឹងប៉ា! ដើមឡើយគេធ្វើហ្នឹងដើម្បីឲ្យប៉ាម៉ាក់ត្រូវគ្នាវិញ ដឹងអីកូនឯងចាប់ Johanបាន។ មិនតែប៉ុណ្ណឹងហៅប្អូនស្រីចុងគេទៅប្រាប់ឲ្យដឹងរឿងទៀត! គេថាយើងទំនេរពេកទៅលូកដៃរឿងផុនគេ! ខូចគម្រោងការពុកម្ដាយគេហើយធ្វើឲ្យបងប្អូនគេយល់ខុសនឹងគ្នាទៀត?»

យុត្តនានៅស្ងៀមសម្លឹងតែមតុ។ ដំបូងគេរួសរាយ ព្រោះមកជួបឪពុកតែឮឈ្មោះសុភាពបុរសក្លែងក្លាយនោះកាលណាចិត្តគេ រមាស់ឡើងមួយរំពេច។
រូបរាងនិងកាយវិការស្រីតូចមេធាវីក៏អណ្ដែតមកវិញក្នុងគំនិតអ្នកដែរ។
«នាងមិនត្រឹមតែមិនខឹងបងប្រុសសំអុយរបស់នាង ថែមទាំងទៅប្រាប់ថាចូហាន់នៅឯណាទៀត?» គេរអ៊ូតិចៗនៅចំពោះឪពុកធ្វើឲ្យអគ្គទេសាភិបាលថ្លោះទឹកមុខ។
មានតែលេខាប៉េងទេដែលដឹងថា ទោះបីឧកញ៉ា ប៉ែន ពេជ្រ គឺជាគូបដិបក្ខឆ្លងទសវត្សរ៍របស់ ហួត ស៊ីវ ប៉ុន្តែមិនដឹងយ៉ាងម៉េចបុរសនេះបែរជាមានទំនាក់ទំនងល្អណាស់ជាមួយ ប្រពន្ធមុននិងកូនទាំងបីរបស់គាត់ ក្នុងនោះប៉ែន ពេជ្រប្រាថ្នា គឺជាយុវជនដែលត្រូវបាន ហួត ស៊ីវ រាប់អានរាក់ទាក់ជិតដិតដល់ថ្នាក់អាចប្រឹក្សារឿងរ៉ាវទាំងផ្ទាល់ ខ្លួនទាំងពាណិជ្ជកម្មបានដោយមិនរើសពេលវេលា។

ពាក្យដែលបុរសក្មេងចិត្តស្លូយដៀលនាយប្រាថ្នាថាជាបងប្រុស សំអុយរបស់ពៅបញ្ញានោះពិតជាធ្វើឲ្យទើសដល់បេះដូងលោកប៉ាធម៌នេះប្រាកដមែន។ គាត់មិនអាចទប់ចិត្តមិនហាបន្ទោសឡើយ៖
«ដែលកូនឯងជេរគេហ្នឹងមានឈ្យោកមើលខ្លួនឯងខ្លះទេ! អ្ហះយុត្តនា? គេអាយុប៉ុណ្ណឹងកាន់កាប់សាជីវកម្មរកស៊ីអចលនទ្រព្យល្បីឈ្មោះកប់ ពពក! កូនឯងខ្លួនឯងបានលទ្ធផលអីខ្លះហើយ? មានគោលដៅអីខ្លះហើយក្រៅតែពីសេពគប់ពួកក្មេងៗកាងកាប់ដាវដើរស៊ើប ពីអ្នកនេះអ្នកនោះ! លើកនេះនៅមិននៅឲ្យគេខលមកប្ដឹងពុក បើកូនឯងនៅចេះគិត ឆាប់លែងអាគាត់ Johan ហ្នឹង ឲ្យទៅគេវិញទៅ! ក្រោយៗរឿងដែលមិនពាក់ព័ន្ធនឹងយើង កុំទៅរវល់! កោតណាស់ការងារឪពុកមួយគំនរមិនចេះមកឈ្យោកជួយមើលមុខក្រោយ គិតពីទៅជួយគិតសត្រូវ? កូនឯងអាណិតវាខ្លាចវាអត់លុយសងភាគហ៊ុន? ខ្លាចវាជាប់គុកណាស់? កុំភ្លេចណ៎ាប៉ាឯងស្លាប់យ៉ាងម៉េចមុនពេលប៉ាយកឯងមកចិញ្ចឹម? វាគឺមិត្តទ្រុស្តមិត្ត! វាមិនមែនជាញាតិនឹងឯងដូចមុនទេយុត្តនា!»

យុត្តនាមិននិយាយតបសូម្បីមួយម៉ាត់។ តែភាពមិនសប្បាយចិត្តដែលកំពុងលេចឡើងក្នុងពន្លឺភ្នែកគេធ្វើឲ្យ លេខាប៉េងព្យាយាមជួយនិយាយសម្រួលបរិយាកាសៈ
«អ្នកប្រុសធ្វើអញ្ចឹងតាមមើលក៏មិនមែនមានន័យចង់ជួយឧកញ៉ា ប៉ែន ពេជ្រ ដែរ គឺចង់ឱបដៃមើលពីរនាក់បងប្អូននោះខាំគ្នាទេទានប្រុស!»
គឺជាទម្លាប់របស់យុត្តនាទៅហើយដែលមិនតមាត់ជាមួយឪពុកធម៌រាល់ ពេលលោកអគ្គទេសាភិបាលខឹងម្តងៗ។ គេបានត្រឹមនៅស្ងៀមមិនមានប្រតិកម្ម តែ ហួត ស៊ីវ និងលេខាគាត់ដឹងច្បាស់ណាស់ថា គ្មានអ្នកណាអាចផ្លាស់ប្តូរគោលដៅរបស់កូនប្រុសធម៌ម្នាក់នេះឡើយ ប្រសិនបើគេមានបំណងឆ្ពោះទៅកាន់ទីណាហើយនោះ។
នៅពេលដែលបុរសចំណាស់ទាំងពីរផ្លាស់គ្នានិយាយម្នាក់បូកម្នាក់ដក យុត្តនានៅស្ងៀមទ្រេតខ្នងលើបង្អែកកៅអី។
និយាយអស់ចិត្ត ហួត ស៊ីវ ងៀងភ្នែកមើលមកមនុស្សជំនិតរបស់ខ្លួន។ គាត់ឈប់និយាយហើយ.... តែភ្នែកគាត់មានអត្ថន័យជាសំងាត់ប្រាប់គ្នាថា «អាក្មេងនេះ មានចរិតមិនខុសពីឪពុកបង្កើតវាសោះ!»

កាលពីប្រមាណជិតសាមសិបឆ្នាំមុន យុវជន ប៉ែន ពេជ្រ ហួត ស៊ីវ វ៉ាយុទ្ធ និងទេវរាជ គឺជាមិត្តល្អនឹងគ្នា។ ពួកគេជាក្រុមតែមួយ បង្ហាញខ្លួននៅទីណាគឺមានមុខទាំងអស់គ្នា តាំងពីវិទ្យាល័យរហូតដល់មហាវិទ្យាល័យ។ ប៉ុន្តែការជួបជុំណាមួយក៏គង់មានការបែកខ្ញែក ឯចំណែកមិត្តភាពយុវវ័យក៏គង់មានថ្ងៃផុយស្រួយនៅពេលណាមួយ ដែលទំនាស់ផលប្រយោជន៍បង្ហាញខ្លួនក្នុងចំណងមនោសញ្ចេតនារបស់ពួកគេ។
ហួត ស៊ីវ គឺជាកូនប្រុសទោលនៃគ្រួសារអ្នកជំនួញចិនដែលជាអ្នកប្រកបអាជីវកម្ម ទិញលក់ត្បូង មាសនិងគ្រឿងអលង្ការផ្សេងៗ។ ជីវភាពរបស់គេគឺធូរធារជាងគេឯងក្នុងចំណោមមិត្តភ័ក្តិ។ ចំណែក ប៉ែន ពេជ្រ ជាគ្រួសារអ្នកច្បាប់ដែលមានឪពុកជាមេធាវី តែខ្លួនគេមិនរៀនមុខវិជ្ជានេះឡើយព្រោះមានទេពកោសល្យជាសហគ្រិន ច្រើនជាងការស្រលាញ់សៀវភៅច្បាប់។ ទេវរាជជាយុវជនដ៏មានគំនិតច្នៃប្រឌិត គេមកពីខេត្ត ប៉ុន្តែបានក្លាយជាសិស្សល្បីប្រចាំសាលានិងបន្ទាប់មកប្រចាំប្រទេស ។ នៅមុនបញ្ចប់ឆ្នាំទីបួននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រគេបានរក ប្រាក់យ៉ាងច្រើនពីគម្រោងជំនួញទី១ដែលបានលក់ទៅឲ្យសាជីវកម្ម ខ្មែរមួយ នាំមកនូវប្រាក់ចំណូលលានដុល្លារដល់ក្រុមហ៊ុននោះ។មិនទាន់ទទួលបាន បរិញ្ញាបត្រផង ទេវរាជ

ត្រូវបានក្រុមហ៊ុនធំៗជាច្រើនទាក់ទងឲ្យធ្វើជាទីប្រឹក្សា គម្រោងដែលមានភាគហ៊ុនស្មើនឹងគេរកស៊ីរាប់សិបឆ្នាំ។ ទេវរាជបានត្រូវមិត្តបីនាក់ទៀតកោតស្ញប់ស្ញែងហើយលើកតម្កើងជា មេក្រុមក្នុងចំណោមពួកគេ។ ពិសេសគឺ ហួត ស៊ីវ នៅពេលដែលគេកាន់តែដឹងក្តីហើយកាន់ការអ្វីជំនួសគ្រួសារ គេកាន់តែរៀបគម្រោងការចូលទៅជិតទេវរាជរៀនសូត្រពីរបៀបកសាងគម្រោងជំនួញនិងធុរកិច្ចដ៏អច្ឆរិយនេះ។

គម្រោងមួយដែលជាគម្រោងចុងក្រោយមុនពេលទេវរាជស្លាប់មានឈ្មោះថា «រតនៈសោភ័ណ»ជាគម្រោងទាក់ទងនឹងរ៉ែត្បូងរាប់សិបហិចតានៅភាគ ឦសាននៃប្រទេសកម្ពុជា ដែលពេលចាប់ផ្តើមសិក្សានិងតាក់តែងគម្រោងនេះទេវរាជបានប្រាប់ មិត្តទាំងបីថា «វាគឺជា Project ដែលធ្វើឲ្យយើងអាចក្លាយជាមហាសេដ្ឋីបានដោយខ្លួនឯងហើយមិនចាំបាច់ ធ្វើការឲ្យអ្នកណាគេទៀតនោះឡើយ! Project នេះមានតម្លៃរាប់រយឆ្នាំផ្សារភ្ជាប់ទៅនឹងធនធានរតនសម្បត្តិត្បូង ថ្មដ៏វិសេសវិសាលរបស់ខ្មែរយើងនៅខេត្តរតនគិរី ហើយវាក៏ជាការវិនិយោគដែលផ្តល់មកនូវលទ្ធផលជាចិរភាព ព្រមទាំងអាចអភិរក្សធនធានត្បូងធម្មជាតិឲ្យគង់វង្សយូរអង្វែង! យើងបានដាក់ការព្យាយាមនិងចំណេះដឹងព្រមទាំងការស្រាវជ្រាវរបស់យើង ទាំងអស់ទៅក្នុងគម្រោងការនេះ សូម្បីតែប្រទេសយើងត្រូវអាក់ខានដោយសង្គ្រាមឬវិបត្តិសេដ្ឋកិច្ចណាមួយក៏វាអាចយកត្រូវបានប្រើក្នុងពេល១០០ឆ្នាំទៀតដែរ!»។
ទេវរាជបានស្លាប់បន្ទាប់ពីនោះពីរខែ ហើយគម្រោងចុងក្រោយដ៏ល្បីនិងគួរឲ្យស្រើបស្រាលនោះត្រូវបានគេដឹង ធ្លាក់ក្នុងដៃមិត្តជិតដិតម្នាក់ក្នុងចំណោមមិត្តទាំងបីរបស់ គេ។
នោះគឺ«ប៉ែន ពេជ្រ» មិនមែន«ហួត ស៊ីវ»។

## ៦

«ជំនួយការដ៏ជំនិតរបស់ឧកញ៉ា ប៉ែន ពេជ្រ»

…..ខ្យល់ត្រជាក់បោកបក់រុក្ខជាតិតូចធំនៅតាមបណ្តោយស្រះជីកធំ មួយជាបរិវេណលំហែនិងហាត់ប្រាណសម្រាប់តែបណ្តាអភិជនប៉ុណ្ណោះ។
ដោយសារនេះជាខែរងាសម្រាប់ក្រុងភ្នំពេញដែលសឹងថាគ្មានរស្មីព្រះអាទិត្យ គេមិនឃើញមានអ្នកមកហាត់ប្រាណច្រើនទេ។
ហួត ស៊ីវ អាចប្រើបរិយាកាសអំណោយផលនេះនិយាយចេញមកនូវទុក្ខសោករបស់គាត់។

«ក្នុងមួយជីវិតរបស់ខ្ញុំ មានតែគម្រោងធុរកិច្ច រតនៈសោភ័ណ មួយគត់ដែលធ្វើឲ្យខ្ញុំដេកមិនកើតស៊ីមិនបានរាប់សិបឆ្នាំ មកនេះ!»

ហួត ស៊ីវ និយាយប៉ែឡាំៗរបៀបចិនតែទឹកមុខគាត់បង្ហាញចេញនូវក្តីឈឺចាប់ដែលកប់យ៉ាងជ្រៅក្នុងក្រអៅបេះដូង។

លេខាប៉េងបុរសខ្មែរកាត់ចិនដ៏ជំនាញខាងផ្តល់យោបល់និងយកចិត្ត ថ្លើម បានស្ទុះមកគ្រាថៅហ្វាយធំដោយសារគាត់ប្រឹងរត់ត្រឹកៗហាត់ប្រាណ បណ្តើរនិយាយបណ្តើររហូតដល់ហត់គយូសទៅមុខលែងចង់រួច។

....ជំនោរកត្តិករំភើយៗបក់មកធ្វើឲ្យបុរសចំណាស់ទាំងទ្រាំរងា ទាញអាវក្រៅរូតភ្ជិតខ្លួន។

«ខ្ញុំចាស់យ៉ាងនេះហើយ! ខ្ញុំនៅតែមិនទាន់បានរបស់នោះ! ឯងថាទៅមើលប៉េង ទេវតាចង់សាកខ្ញុំឬក៏ធ្វើបាបខ្ញុំ?»

ជនក្រោមបង្គាប់នៅតែមិននិយាយអ្វីបានត្រឹមចូលរួមស្តាប់ភាពតឹងតែងរបស់ថៅហ្វាយ។

ហួត ស៊ីវ កាន់តែរំជួលចិត្តគាត់កាន់តែនិយាយក៏កាន់តែមិនសុខចិត្ត។ គាត់បន្ថែមសំណួរទៀត៖

«ខ្ញុំក៏ជាមិត្ត អាពេជ្រក៏ជាមិត្ត ហេតុអីមុនស្លាប់បងរាជឲ្យគម្រោងការនោះទៅវាហើយគាត់រំលងខ្ញុំ ដែលតាមរៀនតាមយកចិត្តគាត់រាល់ថ្ងៃ?»

«លោកអគ្គ! ប្រយ័ត្នសុខភាពផង! ឈប់ខឹងទៅ! សម្រាកលើបង់ថ្មនេះសិន! ខ្ញុំរត់ទៅឡានយកទឹកមក!»

ហួត ស៊ីវ មិនមាត់តែភាពចងកំហឹងបង្ហាញចេញតាមបបូរមាត់និងចុងច្រមុះ។ ភ្នែកគាត់សម្លឹងទៅឆ្ងាយ ហើយរក្សាការស្ងាត់ស្ងៀមក្នុងពេលដែលលេខាប៉េងរត់ទៅឡានយក ភេសជ្ជៈ។

....ហួតស៊ីវ ប្រើពេលនៅឯកានេះនឹកឃើញដល់យុវភាពរបស់គេ។

ទឹកមុខនិងស្នាមញញឹម សូរសំណើចក្អាកក្អាយមិត្តទាំងបួនកាលលេងបាល់ជាមួយគ្នាលេចឡើងមក រួមជាមួយតំណក់ទឹកភ្នែក ពេលដែលទេវរាជទៅលែងវិលមកវិញ។

តែភ្លាមនោះគេនឹកឃើញដល់រង្វង់មុខពងក្រពើរបស់ស្រីម្នាក់....

ប្រយោគសន្ទនាដ៏គួរឲ្យឈឺចាប់តាំងពីច្រើនឆ្នាំមកហើយ លាន់មកវិញរងំហាក់នៅចំពោះមុខ....

«បង! យើងត្រូវបែកគ្នា...! យើងជម្នះមិនបានទេ! អូនគិតរួចហើយ! លោកប៉ាជាត្រកូលអ្នក

ច្បាប់គ្រប់ជំនាន់ អ្នកម៉ែជាខ្មែររាជវង្ស លោកប្រកាន់បំផុតរឿងផ្សំផ្គុំកូនឲ្យអ្នករកស៊ីហើយ ពិសេសគឺគ្រួសារ បងកាត់ចិនទៀត! អ្នកម៉ែជាអ្នករបៀបបំផុតការរស់នៅរបស់យើងខុសគ្នាហៅមិនឮ! យប់មិញអូនបានសាកល្បងអង្វរលោកទាំងពីរទៀតហើយ តែលោកថា ដាច់ខាតខែក្រោយនេះ អូនត្រូវរៀបការជាមួយ ប៉ែន ពេជ្រ! »

«កុសុមា! បងខុសអី? បងជាកូនចិនវាយ៉ាងម៉េច! បងរកស៊ីមែន និយាយខ្មែរអត់បានល្អមិនដឹងរបៀបក្នុងវាំង តែបងមានអ្វីៗទាំងអស់ អាចឲ្យអូនរស់នៅសុខស្រួល! ប៉ែន ពេជ្រ មានប៉ាជាមេធាវីតើយ៉ាងម៉េច? វាមានអីគ្រាន់ទៅ វាមានបានរៀនច្បាប់ស្អីវ៉ា? រកស៊ីក៏មិនឃើញអីលូតអស្ចារ្យដែរ! ហេតុអ្វីម្នាក់ៗសុទ្ធតែរើសយកវ៉ា? បងរាជស្លាប់ក៏ឲ្យគម្រោងរតនៈសោភ័ណទៅវ៉ា? ហេតុអី? ហេតុអី?»

កញ្ញាត្រកូលខ្ពស់ យំអណ្ដឺតអណ្ដក។

សក្ខកុសុមា ដើមឡើយជាសង្សាររបស់ ហួត ស៊ីវ តែទីបំផុតនាងមិនអាចជម្នះគ្រួសារបានត្រូវរៀបការជាមួយប៉ែន ពេជ្រ ដែលជាឪពុកពៅបញ្ញាសព្វថ្ងៃ។ ចំណែកហួត ស៊ីវ បានរស់នៅដោយឈឺចាប់មកទល់នឹងសព្វថ្ងៃនេះដោយមិនបានរៀបការឡើយ។

គាត់ភ្ញាក់មកវិញជាមួយខ្យល់ត្រជាក់នឹងសំឡេងដ៏ពីរោះពិសាមួយក្បែរត្រចៀក៖

«លោកប៉ាពិសាទឹក!»

គាត់ងើបមុខសម្លឹងម្ចាស់ហត្ថាធំមាំដែលហុចទឹកមក។ គេគឺជាកូនប្រុសធម៌ ទីពីរដែលមានអាកប្បកិរិយាខុសប្លែកដាច់ឆ្ងាយពីយុត្តនា។

«អង្គុយមកកូន! មកដល់ពីអង្កាល់!»

រិទ្ធិញញឹម ហើយអង្គុយចុះថ្នមៗក្បែរឪពុក។

«កូននឹកលោកប៉ាណាស់! នេះជាពេលល្អបំផុតដែលយើងអាចជួបគ្នាដោយគ្មានគេឃើញ!»

ហួត ស៊ីវ រវេ្ភកសម្លឹងទៅម្ខាង ក៏ឃើញលេខាប៉េងកំពុងរត់ត្រឹកៗទុកឱកាសឲ្យឪពុកកូនបានជជែកដោយសេរី។

«ដំណើរការខាងផ្ទះអាពេជ្រម៉េចហើយ?»

រិទ្ធិដូរទឹកមុខ។

ជនបង្កប់ដ៏ស្រស់សង្ហា តាមពិតគឺចង់ចំណាយពេលចុងសប្ដាហ៍នេះមកលេងឪពុកជាឯកជនក៏មិន ចង់និយាយ អ្វីពាក់ព័ន្ធនឹងការងារឡើយ តែហួត ស៊ីវ ទេដែលមិនយល់ចិត្តនាយ។

គាត់បន្ថែមប្រយោគទីពីរ៖
«វានៅតែបន្តិចទៀតបានដើរចូលទ្រុងហើយ! នៅមិននៅយុត្តនាវាទៅចេញមុខជួយរកអា Johanឃើញ! ស្អីៗរលាយអស់! ពិបាកណាស់ទម្រាំប៉ាបញ្ចុះបញ្ចូលប៉ែន ពេជ្រប្រាថ្នា ឲ្យធ្វើបាបឪពុកវាបាន ឥឡូវការខំមកទាំងអស់រលាយដូចអំបិល!»
ដល់វេនជំនួយការរិទ្ធិនៅស្ងៀមវិញម្តង។

និយាយពីជីវិតជាជនបង្កប់សម្រាប់មនុស្សល្អដូចរិទ្ធិ នេះជាបេសកកម្មដ៏តឹងទ្រូងមួយ។ គេត្រូវបានឪពុកធម៌បញ្ជូនទៅនៅក្បែរឧកញ៉ា ប៉ែន ពេជ្រ តាំងពីនៅជំទង់។
ក្រៅពីយុត្តនា និងលេខាប៉េង គ្មានអ្នកណាដឹងពីទំនាក់ទំនងស៊ីជម្រៅរវាងរិទ្ធិ និងអគ្គទេសាភិបាលហួត ស៊ីវ ឡើយ។
ពេលឪពុកធម៌សួរនាំនិងរៀបរាប់ពីករណីជនបោកប្រាស់ Johan រិទ្ធិកាន់តែគ្មានពាក្យអ្វីនឹងនិយាយព្រោះថា តាមពិតយុត្តនាក៏បានដំណឹងនោះពីអ្នកដែរ។
គឺអ្នកដឹងដំណើរការល្បិចកលទាំងអស់របស់ឪពុកធម៌ក្នុងការរុញឲ្យ ឧកញ៉ា ប៉ែន ពេជ្រ ចូលគុក ប៉ុន្តែ នាយមិនដាច់ចិត្ត.... ពិសេសគឺចិត្តដែលមានលើកូនស្រីពៅរបស់គាត់។ ដូច្នេះបានជារិទ្ធិប្រើមធ្យោបាយទៅរកយុត្តនាឲ្យចាប់ខ្លួននាយ Johan នោះបកអាក្រាត ប៉ែន ពេជ្រប្រាថ្នា។

ឃើញគេនៅស្ងៀម ហួត ស៊ីវ យល់ថា តាមចរិតលក្ខណៈរបស់រិទ្ធិគេមិនដែលលូកមាត់ពេលឪពុកបន្ទោសអ្នក ផ្សេងនៅចំពោះមុខខ្លួនឡើយពិសេសកូនប្រុសធម៌ទីមួយយុត្តនា។ ដូច្នេះហើយលោកអគ្គទេសាភិបាលបង្វែរសាច់រឿងចេញពីនេះវិញភ្លាម៖
«ពៅបញ្ញាឲ្យឪពុកវាដឹងឬនៅថា បងប្រុសវានៅពីក្រោយរឿងបោកប្រាស់នេះ?»
រិទ្ធិឆ្លើយតបយឺតៗ៖
«តាមមើល នាងនឹងមិននិយាយទេ! ឧកញ៉ាកំពុងសម្រាន្តឈឺលើគ្រែ!»
ពាក្យគួរសមរបស់គេសម្រាប់ឧកញ៉ា ប៉ែន ពេជ្រ ជាសត្រូវដ៏ធំក្នុងជីវិតខ្លួនធ្វើឲ្យ ហួត ស៊ីវ ទម្លាក់ទឹកមុខ ។ ជាក់ស្តែងគេមិនសប្បាយចិត្តទេដែលកូនធម៌ខ្លួនស្លូតៗយ៉ាងនេះ សូម្បីពីក្រោយខ្នងហើយ នៅតែហៅសត្រូវគួរសមម្លឹងៗ តែគេសង្កត់ចិត្តសួរកូនប្រុសមួយៗ៖
«កូនទៅនៅឆ្ងាយពីប៉ាយូរហើយ! បានដំណឹងអីខ្លះពី Project នោះ?»
រិទ្ធិឈ្ងោកមុខ។ សកម្មភាពរបស់គេធ្វើឲ្យបុរសចំណាស់នោះដឹងជាស្រេចនូវចម្លើយ។ គាត់

និយាយទាំងងក់ក្បាលថ្ងក់ៗ៖
«ប៉ាដឹងៗ! កញ្ច្រោងកញ្ចាស់នោះវាមិនមែនងាយស្រួលបញ្ចេញកន្ទុយមកទេ! សូម្បីតែពេលវាទាល់ ច្រកដល់ថ្នាក់នេះហើយ វានៅតែមិនដាក់គម្រោងនោះចេញមកដេញថ្លៃយកលុយ! អស្ចារ្យមែន!»
រិទ្ធិរវេភ្នែកសញ្ជឹងគិតតែម្នាក់ឯង.... ជាច្រើនឆ្នាំមកនេះអ្នកកំលោះមិនដែលឮសូម្បីតែមួយពាក្យណាដែល ទាក់ទងនឹងគម្រោងការ«រតនៈសោភ័ណ»នេះចេញពីមាត់ឪពុកពៅបញ្ញាឡើយ ចុះហេតុអ្វីបានជាឪពុកធម៌ខ្លួននៅឯណោះអន្ទះសាម្លេះៗ? គាត់ពេលនេះជាអគ្គទេសាភិបាលជាបុគ្គលដ៏មានជោគជ័យសឹងថានៅគ្រប់គ្រង លើរលកវូបិយប័ណ្ណប្រទេសទៅហើយ ម្ដេចនៅតែចិញ្ចឹមចិត្តចង់បានគម្រោងការនោះ?

តើវាពិតជាគម្រោងការដ៏មហិមាដែលមានតម្លៃជាងទ្រព្យសម្បត្តិដែល គាត់មានក្នុងពេលនេះទៀត ឬមួយគ្រាន់តែមកពីគាត់មានះនិងមិនអស់ចិត្តទេ?
«លោកប៉ា! កូននៅតែសង្ស័យថា តាមពិតលោកទេវរាជមុនស្លាប់ពិតជាបានផ្ទេរ រតនៈសោភ័ណមកឲ្យឧកញ៉ា ប៉ែន ពេជ្រ មែនឬមួយវាគ្រាន់តែជាចចាមអារ៉ាម?»
ហួត ស៊ីវ សើចខឹកៗមិនស្ដីធ្វើឲ្យរិទ្ធិប្រញាប់ពន្យល់បន្ថែមពីគំនិតនាយ៖
«ព្រោះថា១០ឆ្នាំមកនេះ សូម្បីមួយម៉ាត់ ក៏មិនដែលឮគាត់និយាយទាក់ទងនឹងគម្រោងការនេះដែរ! ចុងក្រោយពេលគាត់ទាល់ច្រកខ្លាំង គាត់សុខចិត្តសូម្បីតែខលទៅយុត្តនាជាក្មេងដែលមិនគោរពគាត់និង ស្អប់មុខគាត់ដើម្បីសុំជំនួយហេតុអ្វីគាត់មិនបញ្ចេញគម្រោងការដើម្បីដេញថ្លៃ?»
ហួត ស៊ីវសើចញឹមៗ៖
«ប៉ែន ពេជ្រចំណាស់នេះហើយ វាមានរឿងអីមិនដឹងថា ករណីបោកលុយ១១លានមិនមែនជាក្រឡា អុកចុងក្រោយដែលអាចធ្វើឲ្យវាទ័លបាននោះ កូន!?»
«ប៉ុន្តែ មេធាវីពៅបញ្ញាដាច់ចិត្តឡើងទៅជួបប្រុសអ្នកលេងម្នាក់ដែលខ្វះ ការគោរពដល់នាងទាំងយប់អធ្រាត្រ នាងគឺទាល់ច្រកពិតណាស់! ឬមួយសូម្បីតែនាងក៏មិនដឹងថាឪពុកខ្លួនមានគម្រោងការអច្ឆរិយនោះ ក្នុងដៃដែរ?» គេតបវិញតាមភាពស្លុងអារម្មណ៍របស់ខ្លួន។
«ថាម៉េច? យុត្តនាហៅក្មេងស្រីនោះទៅជួបទាំងយប់?» ហួត ស៊ីវចងចិញ្ចើម។ ដឹងថាខ្លួនជ្រុលមាត់រិទ្ធិនៅស្ងៀមវិញតែឪពុកធម៌ដេញដោល៖

«វាធ្វើអ្វីផ្ដេសផ្ដាសខ្លះ?»
«តាមមើលអត់ទេប៉ា! យុត្តនាលេងសើចច្រើនតែមិនឃើញធ្វើអ្វីពៅបញ្ញាទេ!»

រិទ្ធិតាមពិតគិតពីរឿងផ្សេង។ គេខ្លាចឪពុកធម៌ច្រទ្បំថា យុត្តនា បង្ខំខ្លួនប្រាណពៅបញ្ញា ប៉ុន្តែ អ្វីដែលហួត ស៊ីវគិតមិនត្រឹមតែប៉ុណ្ណឹងឡើយ។ គេរវេក្មកទៅរកលេខាប៉េងដែលនៅរត់ត្រឹកៗ ចុះឡើងៗក្បែរនោះបង្អើយ។
«កូនប្រុសច្បងខ្ញុំ អាចនៅមានមនោសញ្ចេតនាស្នេហាជាមួយក្មេងស្រីផ្ទះនោះទេដឹងប៉េង?» គាត់សួរស្ទើរលេងស្ទើរមែន ប៉ុន្តែធ្វើឲ្យបេះដូងរិទ្ធិញ័ររង្គើ។
ពិបាកនិយាយដែរ ហេតុអ្វីគេទៅរកយុត្តនាឲ្យបញ្ចេញដៃជើងចាប់ Mr. Johan នោះយុត្តនាក៏ ព្រមធ្វើតាមភ្លាម?
លេសរបស់គេគឺថាគេនឹងធ្វើឲ្យកូនស្រីសត្រូវមករកគេ អង្វរគេ ហើយធ្វើឲ្យនាងឈឺចាប់ ដោយសារតែដឹងថាបងប្រុសខ្លួនក្បត់ឪពុក ខ្លួន។ ប៉ុន្តែបើមើលឲ្យយូរទៅ វាជាគំនុំចៃកមិន ដាច់ស្រលះពីស្នេហ៍ទេដឹង?
សំឡេងលេខាប៉េងលាន់មកសម្រួលបរិយាកាស៖
«គំនុំឪពុកមិនអាចលុបដោយសារសម្រស់ស្រីទេដឹងលោកអគ្គ?! ណាមួយក្មេងស្រីនោះក៏មិន មែនជាស្រីស្អាតដែរ ប្រៀបជាមួយបងស្រីខាងម្ដាយដើមគេ!»
ហួត ស៊ីវសើចខឹកៗ៖
«ប៉េងឯងដូចចង់ពន្យុះខ្ញុំឲ្យដណ្ដឹងកូនស្រីប្រពន្ធដើមរបស់អាពេជ្រឲ្យយុត្តនាឲ្យហើយអញ្ចឹ ង!»

ម្ដងនេះរិទ្ធិកាន់តែគិតមិនយល់ ត្បិតអីអាថ៌កំបាំងជាច្រើននៅតែជាប្រស្នាចាក់ស្រេះច្រើនឆ្នាំ មកនេះ។ ហួត ស៊ីវជាឪពុកធម៌ខ្លួនស្អប់ឧកញ៉ាប៉ែន ពេជ្រ និងកូនស្រីម្ដាយចុងគឺពៅបញ្ញា ណាស់ ព្រតែឈ្មោះក៏ខឹងតែគេបែរជាត្រូវគ្នាជាមួយសំបុកខាងដើមយ៉ាងចម្លែក គឺទទួលកូន ប្រុសច្បងប៉ែន ពេជ្រប្រាថ្នាជាកូនប្រុសធម៌ទីបី ជាសម្ងាត់កូនស្រីពីរនាក់ផ្សេងទៀតក៏នៅក្នុង គម្រោងរើសយកម្នាក់ មកជាគូជីវិតរបស់យុត្តនាទៀត បើតាមឃ្លាសន្ទនាបញ្ឆិតបញ្ឆៀងនេះ? ស្អប់ឪពុក តែត្រូវកូន?
«លោកប៉ាអត់ចូលចិត្តឧកញ៉ាប៉ែន ពេជ្រទេ! លោកពូប៉េងឲ្យយោបល់មិនត្រូវបរិយាកាស ហើយថ្ងៃនេះ! លោកប្រាកដជាគ្មានផ្លូវព្រមធ្វើដន្លងនឹងគ្រួសារនោះឡើយ!»

រិទ្ធិនិយាយបញ្ឆិតបញ្ឆៀងដើម្បីស្ទាបស្ទង់ចិត្តសាស្ត្រ។
ដឹងអីហ្វួត ស៊ីវពន្យល់មកវិញធ្វើហី៖
«កំហុសឪពុកមានអីទាក់ទងនឹងកូន? ក្មេងៗនោះជាកូនម្តាយដើមដែលត្រូវឪពុកបោះបង់ចោល គួរឲ្យអាណិត ម្តាយក្មេងនោះក៏ជាមិត្តចាស់ ប្រាថ្នា អមរា និងសក្ខណា សុទ្ធតែជាក្មេងល្អ!»។
លេខាប៉េងងាកមុខចេញ នៅពេលដែលស្តាប់ឮប្រយោគទីទើររបស់ហ្វួត ស៊ីវចំពោះឈ្មោះកូនទីបីរបស់ប្រពន្ធដើម ប៉ែន ពេជ្រ ដែលចៅហ្វាយខ្លួនទើបនឹងរំលឹក។

មានតែមនុស្សជំនិតនេះទេដែលដឹងថា ប៉ែន ពេជ្រប្រាថ្នា និងប៉ែន ពេជ្រអមរា គឺជាកូនភ្លោះដែលជំទាវសក្ខកុសុមាមានក្នុងផ្ទៃមុនថ្ងៃចូលរោង ជាមួយឧកញ៉ាប៉ែន ពេជ្រម៉្លេះ។
ដូច្នេះឪពុករបស់ពួកគេទំនងជាសង្សារចាស់នៃលោកជំទាវត្រកូលរាជវង្ស ហើយសង្សារម្នាក់នោះគ្មានអ្នកណាក្រៅពីបុរសមានទ្រព្យដ៏ជោគជ័យតែ គ្មានប្រពន្ធមកទល់តែសព្វថ្ងៃនេះឡើយ។ ហ្វួត ស៊ីវនិយាយថា បើតែចិត្តគាត់បេះដូងគាត់គឺសំដៅលើតែចំពោះក្មេងភ្លោះពីរប្រុសស្រីពីរនាក់ដំបូងប៉ុណ្ណោះដែលជាសាច់ឈាមគាត់ពិតៗខ្ញីត្រកូលគេ ប្រើជាច្រើនឆ្នាំមកហើយ។
ចំណែកកូនស្រីទីបី ប៉ែន ពេជ្រសក្ខណានោះមិនបានរវល់ជាមួយទេព្រោះជាលទ្ធផលនៃស្នេហាបង្ខំ ចិត្តរបស់ជំទាវនិងស្វាមីស្របច្បាប់ប៉ុណ្ណោះ។
រិទ្ធិឆ្លាតយ៉ាងណាក៏មិនយល់ដល់កលល្បិចទាក់ទងដល់អតីតកាលចាក់ស្រេះ ទាំងនេះឡើយ។ ដែលសំខាន់គឺគេអរគុណវាសនាដែលថាខ្លួនមិនមែនមុខសញ្ញាត្រូវរៀបការ ជាមួយកូនស្រីផ្ទះនោះ បែរជាយុត្តនា។
ក្នុងចិត្តគិតដល់នារីស្រគត់ស្រគំនៃផ្ទះ ប៉ែន ពេជ្រ គឺពៅបញ្ញា។ គេក៏នឹកឃើញដល់គម្រោងការធុរកិច្ចរតនៈសោភ័ណសាជាថ្មី។
គេវាចាតិចៗ៖
«បើសិនឧកញ៉ាពិតជាមានគម្រោងការអច្ឆរិយនោះពិតមែន គាត់លាក់ទុកធ្វើអីយូរយ៉ាងនេះ? វាអាចថា Out of date ប្រើការលែងកើតផងមិនដឹង បានជាគាត់មិនដាក់ឲ្យដេញថ្លៃយកលុយមកបាន»
ហ្វួត ស៊ីវមិនឆ្លើយព្រោះមានតែគាត់ទេដែលដឹងថាគម្រោងការនោះមានអាយុកាល រយឆ្នាំ

ហើយមានភាពបត់បែនបានល្អទៅនឹងប្រវត្តិសាស្ត្រភូមិសាស្ត្រព្រមទាំង រតនសម្បត្តិក្រោមដីរបស់ខ្មែរ។

គាត់បញ្ចេញភាពកាចសាហាវដ៏ជ្រៅក្នុងពន្លឺភ្នែកដែលសម្លឹងទៅកាន់កូនប្រុសធម៌ទីពីរ៖

«ប៉ានឹងធ្វើឲ្យវាបង្ហាញចេញគម្រោងការនោះឆាប់ៗនេះ!»

បុរសក្មេងនៅស្ងៀមព្រោះមិនដឹងពីអ្វីដែលកំពុងលេចឡើងក្នុងចិត្ត ឪពុកធម៌ ហើយគេក៏មិនហ៊ានសួរដែរ ដូច្នេះអគ្គទេសាភិបាលសម្បូរល្បិចសើចស្រាលៗហើយទះស្មាគេថ្នមៗ។

«ថ្ងៃនេះជាថ្ងៃអាទិត្យ នៅកំដរប៉ាពេញមួយថ្ងៃបានទេ?»

«បាទ!»គេប្តូរទឹកមុខទៅជាញញឹម.....

## ៧

គម្រោងធុរកិច្ច « រតនៈ សោភ័ណ »

....បុរសបង្កប់មកដល់ផ្ទះឧកញ៉ាប៉ែន ពេជ្រនៅយប់ដដែលទោះបីនេះជាពេលសម្រាកក៏ដោយ។

បើមើលពីក្រៅទៅ គេដូចជាមានការបារម្ភខ្លាំងព្រោះថាចៅហ្វាយនាយនៅមានបញ្ហាសុខភាពនៅឡើយ តែការពិតក្នុងចិត្ត គេមិនដឹងថា ហេតុផលសំខាន់ដែលគេទៅណាមិនឆ្ងាយពីគេហដ្ឋាននេះដោយសារអ្នកនាងតូច ពៅបញ្ញាឬក៏គម្រោងការរតនៈសោភ័ណឡើយ។

...រិទ្ធិដើរសំដៅទៅកាន់បន្ទប់ឧកញ៉ា ប៉ែន ពេជ្រ ល្មមពេលពៅបញ្ញាទើបនឹងចេញមកវិញដែរ។ នាងញញឹមស្វាគមន៍នាយ ៖

«បងរិទ្ធិយប់ម្លេះ?»

«បងមកពីបាយជុំសាច់ញាតិទៅផ្ទះវិញ កាត់តាមនេះ ឆ្លៀតឡើងមកមើលឧកញ៉ាថាលោកសម្រាកឬនៅ?»

នារីញញឹម។

ទឹកមុខនាងភាពស្រស់ស្រាយរបស់នាងគឺមានពេញលេញ។

យ៉ាងណាមិញ ភាពធូរស្រាលរបស់នាងជាឱសថទិព្វព្យាបាលទុក្ខកង្វល់របស់នាយ។ គេសម្លឹងនាង ដែលលាក់បាំងរូបសម្រស់ពីក្រោមអាវដំណោកធំរលុងពីរជាន់ ពណ៌លឿងស្រាលវែងអូសលើឥដ្ឋ។ភាពជាអភិជននិងចរិតទន់ភ្លន់ថ្លៃថ្នូរ បានបុកទម្លុះរនាំងបេះដូងអ្នកស៊ើបការណ៍ម្នាក់នេះតាំងពីថ្ងៃមួយ ដែលនាងបានបន្ទាបកាយមករុំរបួសដៃឲ្យនាយនៅឯសួនច្បា

រ។ នាងមិនដឹងទេថានិស្សិតលេខមួយផ្នែកពាណិជ្ជកម្មនេះ តាមពិតគឺជាកូនធម៌ទីពីរនៃសត្រូវចាស់របស់ឪពុកនាង ហើយហោចណាស់គេក៏ជាអ្នកប្រុសទីពីរនៃត្រកូលអគ្គទេសាភិបាល។

នាងបន្ទន់ខ្លួនបន្ទាបដៃមករុំរបួសឲ្យមនុស្សម្នាក់ដែលជា អ្នកបម្រើក្នុងកែវភ្នែកអ្នកផង ធ្វើឲ្យបេះដូងអ្នកកំលោះដែលមិនធ្លាប់មានពេលទៅទទួលនារីណាម្នាក់ មករក្សាទុកនោះ ចាប់ផ្ដើមមានស្រមោលអ្នកនាងតូចយ៉ាងអាថ៌កំបាំងរហូតដល់ពេលនេះគេ ចែកមិនដាច់ទេថា គេនឹងក្លាយជាអ្នកការពារគ្រួសារនេះ ឬក៏ជាអ្នកនាំមកនូវមហន្តរាយ។
«បងរិទ្ធិចូលទៅ! លោកប៉ាកំពុងពិសាតែម្នាក់ឯង!»
«ចុះអ្នកនាងមិននៅជជែកលេងជាមួយលោក?»
ស្រីស្ងួនសើចបង្ហាញស្រទាប់ថ្ពាល់ខណ្ឌចែកជាពីថ្នាក់ក្រហមព្រឿងៗនិងរលើបរលោង៖
«លោកប៉ាចូលចិត្តនិយាយជាមួយបងរិទ្ធិបានយូរៗជាងខ្ញុំស្រាប់ហើយ!»
គេញញឹមលុបចោលភាពម៉ឺងម៉ាត់ក្នុងនាមជាអ្នកជំនួយការដ៏ស្រគត់ស្រគំ៖
«បាន! ខ្ញុំចូលទៅហើយ!»
គេដើរហួសពីនាងទៅតែបេះដូងនៅតែនឹកក្លិនខ្លួនក្រអូបប្រហើរដែលរសាយមក។
«បងរិទ្ធិ!»
ពៅបញ្ញាហៅពីក្រោយតិចៗ ធ្វើឲ្យនរៈបែរទៅរកនាង។ នាងដើរស្រាលៗមកកៀកនឹងនាយជាមួយការស្នើសុំផុសចេញតាមពន្លឺ ភ្នែក៖
«លោកប៉ាច្បាស់ជាសួរនាំរឿងលុយ១១លាននោះ!»

នាងបញ្ឈប់ប្រយោគត្រឹមនេះដោយទឹកមុខបារម្ភ។ រិទ្ធិដឹងថា នាងមិនបានជម្រាបលោកឪពុកពីការដែលនាងព្រមព្រៀងជាមួយយុត្តនា ព្រោះមិនចង់ឲ្យលោកពិបាកចិត្ត ពិសេសករណីដែលប៉ែន ពេជ្រប្រាថ្នាបងប្រុសខុសម្ដាយរបស់នាងនៅពីក្រោយរឿងនេះ។
«ខ្ញុំមិនចង់ឲ្យលោកពិបាកចិត្ត!» នាងបន្ថែមខ្សោយៗ។
រិទ្ធិឃើញភាពសៅហ្មងលេចចេញលើទឹកមុខដែលទើបតែញញឹមស្រស់ មិនដឹងយ៉ាងម៉េចគេហេងហាងអាណិតនាងចម្លែក ប្រសិនបើអាចធ្វើអ្វីមួយដើម្បីដកចេញឲ្យអស់នូវទុក្ខកង្វល់របស់នាង គេមុខតែធ្វើទោះលំបាកយ៉ាងណាក៏ដោយ រហូតដល់ពេលខ្លះគេភ្លេចខ្លួនថា ចូលនៅក្នុងត្រកូលនេះដើម្បីអ្វី?។
«ខ្ញុំយល់ហើយអ្នកនាង!»

ស្រីតូចញញឹមស្រពោន៖
«អរគុណបងរិទ្ធិ!»
នាងបែរចេញទៅក្រោមពន្លឺភ្នែកស្រទន់របស់នាយ។
«ពៅបញ្ញា តើនាងមានទុក្ខលំបាកអ្វីទៀតដែលចង់លាក់កំបាំងពីគ្រប់គ្នាហើយទូលវាតែម្នាក់ឯង?»
អ្នកប្រុសទីពីរគិតបណ្ដើរបែរដើរតម្រង់ទៅរកបន្ទប់ឧកញ៉ាបណ្ដើរ។
គេគោះទ្វារស្រាលៗរហូតដល់មានការអនុញ្ញាតពីបុរសចំណាស់ទើបគេមួលសោដើរចូលទៅ។
...គេដើរហួសពីគ្រែដំណេកឆ្ពោះទៅបន្ទប់រានហាលខាងមុខដែលឧកញ៉ាពោះម៉ាយអង្គុយកណ្ដោចកណ្ដែងម្នាក់ឯងក្រោមពន្លឺខែ។
«ខ្ញុំលែងអីហើយ! ក្មួយគួរទៅផ្ទះសម្រាក!»

រិទ្ធិញញឹមបោះជំហានទៅក្បែរបុរសជានាយថៅហ្វាយ ហើយទម្លាក់បង្គុយក្បែរជើងកៅអីរៀបចំចាក់ ទឹកតែបន្ថែមជូន។
«ឧកញ៉ានៅមិនទាន់ងងុយទៀត? ចាំខ្ញុំនៅកំដរជជែកលេងក៏បាន!»
«ខ្ញុំគ្រាន់តែយល់ថាជីវិតមនុស្សយើងឡើងចុះមិនទៀងសោះ! ពីម្សិលមិញស្ថានភាពតឹងតែងរកតែដកដង្ហើមក៏មិនបាន ចំណែកល្ងាចនេះអ្វីៗប្រែទៅជាដោះស្រាយបានអស់!»
«ឧកញ៉ាសប្បាយចិត្តទើបត្រូវ!» គេនិយាយដោយរក្សាភាពស្រស់ស្រាយលើផ្ទៃមុខ។
គាត់ញញឹមហើយក្រេបពែងតែដែលគេហុចឲ្យ។សម្លឹងទៅផ្ទៃមេឃល្វឹងល្វើយ ឧកញ៉ាប៉ែនពេជ្របន្លឺមួយៗតិចៗស្របតាមបរិយាកាសដ៏ស្ងប់សុខនៃរាត្រីកាលមួយ ដែលទើបតែបញ្ចប់វិបត្តិ៖
«ក្មេងនោះសម្ដីមិនល្អ តែគេនៅតែមានចិត្តជួយពូ ពូចេះតែយល់ថាយុត្តនាមានចរិតមិនខុសពីប៉ាគេទេ!»
រិទ្ធិនៅស្ងៀមមិនឆ្លើយ តែគេដឹងថាលោកកំពុងសំដៅដល់យុត្តនា។

តាំងពីយប់មិញពេលដែលនាងចុះពីបន្ទប់យុត្តនាមកគឺគេបានចាំ ទទួលនាងនៅជាន់ខាងក្រោម Apartment នោះស្រេចទៅហើយ។ ពៅបញ្ញាបានប្រាប់គេទាំងគ្រប់សព្វបែបយ៉ាង តែនាងសុំមិនឲ្យគេនិយាយវាឲ្យលេចឮដល់លោកប៉ាឡើយ។ នាងជម្រាបលោកត្រឹមថា

នាយយុត្តនាមាន Mr. Johan ក្នុងដៃ ហើយគេក៏អាចហៅបុរសនោះឲ្យយកប្រាក់១១លាន មកសងវិញថ្នូរនឹងការ បណ្តេញចេញពីកម្ពុជាដោយមិនប្តឹងប៉ូលិស។

«ក្មេងនោះចេញពីខ្ញុំ ខ្ញុំមិនបានបីបាច់គេដោយផ្ទាល់ដៃដោយសារគេយល់ខុសថាខ្ញុំ ពាក់ព័ន្ធនឹងការស្លាប់របស់ឪពុកគេ! យើងមិនដែលដឹងថា ការរស់នៅរបស់គេច្រើនឆ្នាំមកនេះជួបរឿងរ៉ាវអ្វីខ្លះទេ គេនៅជាមួយអ្នកណា ម្តាយគេសុខទុក្ខយ៉ាងណាទៅហើយ? សម្តីគេគ្រោតគ្រាត ប៉ុន្តែគេនៅតែព្រមជួយយើងនៅពេលយើងពិបាកធ្វើឲ្យខ្ញុំមួយថ្ងៃ ពេញនេះនឹកឃើញដល់យុទ្ធដែលជាឪពុករបស់គេ»

«ឪពុកលោកយុត្តនាជាមិត្តក្នុងចំណោមមិត្តទាំងបួនដែលឧកញ៉ាធ្លាប់រំលឹកកាលពីមុននោះមែនទេទាន?»

«ត្រូវហើយ! ក្នុងចំណោមពួកយើង យុទ្ធក្រជាងគេ! ផ្ទះគេនៅជាន់ទីបួន ប្រក់ស័ង្កសី ក្តៅហប់ពិបាករស់នៅតែគេជាកូនកតញ្ញូហើយក៏ជាសិស្សពូកែ ទោះបីជាគេមិនពូកែដល់បងរាជ! យុទ្ធជាកីឡាករជម្រើសរបស់សាលា ហើយស្រីតាមស្រលាញ់គេក៏ច្រើនដោយសារតែគេមានរាងខ្ពស់សង្ហា!»

និយាយដល់ត្រង់នេះឧកញ៉ាញញឹម។

គាត់បន្តដូចកំពុងនិយាយម្នាក់ឯង៖

«ពេលខ្ញុំមាំជាងនេះ ខ្ញុំចង់ជួបក្មួយយុត្តនាម្តង ដើម្បីបានអរគុណគេ ហើយមើលរូបរាងកម្ពស់កំពគេផង គេដូចយុទ្ធប៉ុណ្ណាដែរ!»

រិទ្ធិសម្លឹងក្នុងពេលគេទ្រេតខ្លួនអង្គុយផ្ទាល់ឥដ្ឋដូចទម្លាប់រាល់ដង។ គេនឹកឃើញភ្លាមដល់ឪពុកធម៌ហួត ស៊ីវ។

ច្រើនឆ្នាំមកនេះ កូនធម៌ទាំងពីររបស់គាត់ពិតជាគ្មានអ្នកណាដឹងហើយស្មានដល់ពី បុគ្គលភាពរបស់ពួកគេឡើយ។ គាត់បានធ្វើឲ្យយុត្តនាស្អប់ត្រកូលនេះ ធ្វើឲ្យរិទ្ធិចូលមកបង្កប់ក្នុងគ្រួសារនេះ។ មិនតែប៉ុណ្ណោះ ក៏ទទួលយកកូនប្រុសច្បងនៃភរិយាដើមរបស់ឧកញ៉ានេះជាកូនធម៌ ផ្គត់ផ្គង់ការរកស៊ីដោយសម្ងាត់ទៀត ក៏ឧកញ៉ាមិនដឹងប៉ុនសរសៃសក់។

ចុងក្រោយហួត ស៊ីវថែមទាំងបានពន្យុះឲ្យកូនប្រុសចាត់ការបោកប្រាស់ប្រាក់ឪពុក ខ្លួនឯងរហូតដល់១១លានដុល្លារបានដោយជោគជ័យ។

បើកុំតែនាយនឹកអាណិតចិត្តពៅបញ្ញានិងមានមនោសញ្ចេតនាជាមួយ គ្រួសារនេះ ហើយរត់ទៅរាយការណ៍បញ្ចុះបញ្ចូលឲ្យយុត្តនាព្រមចាប់នាយ Johan នោះជាថ្នូរនឹងការឲ្យកូនស្រីពីត្រកូលនេះទៅលន់តួគេដល់កន្លែង ទេ លទ្ធផលថ្ងៃនេះក៏មិនដឹងយ៉ាងណាទៅហើយដែរ។ គេបន្លឺសំណួរតិចៗក្នុងបរិយាកាសតឹងតែងថប់បារម្ភ៖

«អគ្គទេសាភិបាលហួត ស៊ីវក៏ជាម្នាក់ក្នុងចំណោមមិត្តល្អទាំងបួនរបស់ឧកញ៉ាដែរ?»

បុរសចំណាស់ឈ្មោះប៉ែន ពេជ្របួរទឹកមុខ។ រិទ្ធិដឹងថាគេស្លុងអារម្មណ៍ហួសដែលសួរសំណួរនេះប៉ុន្តែគេជ្រុល ជាសួរទៅហើយ។

«ត្រូវ! គេហ្នឹងជាមិត្តម្នាក់ដែលមានបានជាងគេក្នុងចំណោមពួកខ្ញុំ! គ្រួសារគេជាថៅកែមាសតាំងពីជីដូនជីតាមក!»

«ឧកញ៉ាកម្របានជួបមិត្តចាស់ណាស់តាមមើល!» រិទ្ធិធ្វើជានិយាយចាក់បណ្តោយ។ តែឧកញ៉ាដកដង្ហើមធំ មុនពេលឆ្លើយ៖

«រិទ្ធិ! គ្មានអ្វីអាចកាត់ផ្តាច់មនុស្សដែលចង់រត់រកគ្នាបានទេ មានតែម្យ៉ាងប៉ុណ្ណោះគឺគេមិនចង់ជួបគ្នា!»

រិទ្ធិមិននិយាយអ្វីទៀតទេតែលោកឧកញ៉ាវិញនៅតែបន្តមករជឹក៖

«បងរាជនិងយុទ្ធស្លាប់ទៅ តាមថាពីរនាក់យើងកាន់តែដឹងសុខទុក្ខគ្នា ប៉ុន្តែគម្រោងការមួយដែលបងរាជបន្សល់ទុក បានធ្វើឲ្យយើងមើលមុខគ្នាមិនត្រង់រហូតដល់ពេលនេះ! ហួត ស៊ីវគេខឹងខ្ញុំព្រោះតែរឿងនោះ»

បេះដូងបុរសក្មេងលោតភឹប ព្រោះជាង១០ឆ្នាំមកហើយ ដែលអ្នកទើបតែឮឧកញ៉ាប៉ែន ពេជ្របង្ហើបពីរឿងដ៏រសើបនេះ។

ពាក្យចាស់និយាយត្រូវណាស់ មនុស្សយើងគ្រាវីករាយបំផុតគឺបន្ទាប់ពីជួបគ្រោះធំហើយមិនអីវិញ។ប្រហែលយប់នេះលោកសប្បាយចិត្ត ព្រោះថាផ្នែកមួយនៃការស្រោចស្រង់ត្រកូលប៉ែន ពេជ្រមកវិញ ក៏ព្រោះតែបានយុត្តនាកូនប្រុសមិត្តចាស់។ បុរសចំណាស់នេះមិនដឹងទេថាឆាកល្ខោនចាក់ស្រេះនៅពីក្រោយរឿងលើក នេះ។

បានជាជ្រុលគាត់បង្ហើបប៉ុណ្ណោះទៅហើយរិទ្ធិសួរបន្តភ្លាម៖

«នោះជាគម្រោងការអ្វីទៅ?»

ឧកញ៉ាប៉ែន ពេជ្រនៅស្ងៀមស្ងាត់មួយខណៈក្រោមភាពក្តុកក្នុងចិត្តរបស់អ្នក ស៊ើបការណ៍។

គេនៅរង់ចាំដោយអន្ទះសា។ ស្រាប់តែសំឡេងជនចំណាស់ពោលមកបន្ត៖
«វាជាគម្រោងការមួយដែលគ្រប់គ្នាក្នុងផ្នែកធុរកិច្ចនាំគ្នាគិតថា វាជាគម្រោងអច្ឆរិយ!»
រិទ្ធិនៅស្ងៀមមិនតប ប៉ុន្តែបេះដូងគេលោតកាន់តែញាប់។
«តើយប់នេះគាត់អាចនឹងភ្លេចខ្លួនបង្ហើបចេញនូវអាថ៌កំបាំងនេះដែរ ឬយ៉ាងណា? តើវាជារឿងល្អសម្រាប់ខ្ញុំដែរទេដែលទទួលបានព័ត៌មានពីវត្ថុនោះ? វាជាអ្វីដែលខ្ញុំតាមស៊ើបច្រើនឆ្នាំមកហើយ.... »
គេនឹងនប៉ុណ្ណាក៏សឹងថាទប់ខ្លួនមិនជាប់ ។
ភ្លាមនោះគេនឹកឃើញដល់ពៅបញ្ញា។
គេស្រាប់តែយល់ថា ដូចជាលឿនពេកហើយក្នុងការដឹងពីគម្រោងការរតនៈសោភ័ណ។ ចុះបើគេដឹងហើយទៅប្រាប់ឪពុកធម៌ភ្លាមតើមានអ្វីកើតឡើង?
ចុះបើគេមិនដាច់ចិត្តនិយាយព្រោះចង់ការពារផ្ទះនេះតើស័ក្តិសមដែរទេដែលឪពុកធម៌មានគុណស្មើឪពុកបង្កើត?
ទីបំផុតក្នុងមួយប៉ប្រិចភ្នែកនោះ រិទ្ធិបែរជាយល់ថាគេមិនចង់ស្តាប់អ្វីទៀតឡើយ!។
«ឧកញ៉ាសម្រាកយកកម្លាំង! នឹងអាលឆាប់ជា! ខ្ញុំគ្រាលោកទៅ!»
គេនិយាយយ៉ាងរួសរាន់កាត់ផ្តាច់អារម្មណ៍អណ្តែតអណ្តូងទៅរកអតីតកាលរបស់បុរសចំណាស់។

៨

## «ស្រីស្អាតបំផុតនៃផ្ទះប៉ែនពេជ្រ ប៉ែន ពេជ្រអមរា»

.....យុត្តនានិងរិទ្ធិគឺជាកូនចិញ្ចឹមរបស់ ហួត ស៊ីវ តាំងពីពួកគេជាកុមារ។ ចំណែក ប៉ែន ពេជ្រប្រាថ្នា ទើបតែត្រូវបាន ហួត ស៊ីវ ទទួលជាកូនប្រុសធម៌ទីបីនៅពេលដែលគេល្បីឈ្មោះក្នុងសង្គម ពាណិជ្ជកម្មទៅហើយ។ ដូច្នេះទំនាក់ទំនងរវាងកូនប្រុសទីបីនិងពីរនាក់ខាងដើមប្រាកដ ណាស់ថា មិនស្និតល្មួត ហើយក៏គ្មានថ្ងៃទៅរួចដែរ ព្រោះយុត្តនាចាត់ទុកគ្រប់គ្នានៃគ្រួសារប៉ែនពេជ្រជាសត្រូវរបស់ គេ ទោះជាកូនប្រពន្ធមុនឬប្រពន្ធក្រោយក្តី។ ចំណែករិទ្ធិដែលមានភារកិច្ចបង្កប់ខ្លួនក្នុងគ្រួសារ ប៉ែនពេជ្រ ម៉េចនឹងអាចឲ្យប្រាថ្នាដឹងថាជំនួយការជំនិតរបស់ឪពុកបង្កើតខ្លួន តាមពិតជាមនុស្សបង្កប់របស់ឪពុកធម៌ខ្លួនទៅ?
«បានន័យថាអាគាត់ប្រាថ្នាវាមិនដឹងថារិទ្ធិឯងក៏ជាកូនប៉ា ដែរទេ?»យុត្តនាសួរទាំងភ្នែកសម្លឹង

គូសន្ទនាជាបងធម៌។
«អត់ទេ! គេដឹងម៉េចនឹងកើត?»រិទ្ធិឆ្លើយតិចៗ។
«ចុះពេលណារិទ្ធិឯងចប់ការងារនៅផ្ទះនោះទៅ?»យុត្តនានិយាយទាំងឈ្ងោក ចុចទូរសព្ទលេងវាហើប៉ុន្តែរិទ្ធិវិញគឺតឹងចិត្តស្ទើរប្រេះទ្រូង។
«អត់ដឹងទេ! ព្រោះមិនដែលមានតម្រុយពីរបស់នោះសោះ!»
«អាProjectឡប់ៗអីនោះមែនទេ?...អត់យល់!!!..ប៉ាជោគជ័យយ៉ាងនេះ គាត់ទៅចង់បានអីគម្រោងការបុរាណហ្នឹង?«រតនៈសោភ័ណ»គ្រាន់ឮតែឈ្មោះ ក៏វាហួសសម័យទៅហើយ! បើវាពិតជាអស្ចារ្យដូចដែលប៉ាគិតមែន ប៉ែន ពេជ្រ ម៉េចនឹងបណ្ដោយខ្លួនឲ្យធ្លាក់ដល់ថ្នាក់នេះ! តានោះឲ្យអាម្សៀJohanបោកលុយបានដល់ទៅ១១លាន ដោយសារគាត់ចង់ធ្វើគម្រោងការថ្មីប្រាសាទស៊ីធី Prasat City មិនអញ្ចឹង? មិនដែលអ្នកណាមានគម្រោងការអស្ចារ្យក្នុងដៃមិនធ្វើទៅធ្វើ គម្រោងការផ្សេងទេ!»

រិទ្ធិលើកពែងកាហ្វេក្រេបតែគេនៅស្ងៀមមិនឆ្លើយអ្វីនឹងបទវិភាគរបស់បងធម៌ឡើយ។ ឃើញគេក្រៀមស្រពោន យុត្តនារវើរវាយគិត។ កាលពីយប់ម្សិល គេនៅចាំបានថា ពេលគេកំពុងធ្វើបាបពៅបញ្ញា រថយន្តរិទ្ធិលូនទៅមកត្រុកៗពីក្រោមផ្ទះគេ។
នឹកដល់ត្រង់នេះ គេសើចខឹកៗ ហើយសម្លឹងពែងកាហ្វេធ្វើឲ្យរិទ្ធិភ្ញាក់ខ្លួនចេញពីទុក្ខកង្វល់។
«សើចអី? មើលទៅឯងសប្បាយចិត្តរាល់តែពេល! មួយរយៈនេះសប្បាយចិត្តណាស់ហ្ន៎យុត្តនា!» រិទ្ធិនិយាយបន្តប់ភាពស្មុគស្មាញលើទឹកមុខខ្លួន។
បុរសសង្ហាម្ចាស់ Apartment លេខ៦ញញឹមមិនឆ្លើយ ធ្វើឲ្យរិទ្ធិសួរបន្ថែម៖
«សម្រេចបំណងក្នុងការធ្វើបាបចិត្តស្រីស្អាតហើយក៏មកអង្គុយសប្បាយចិត្ត?»
យុត្តនាបានចិត្តចងចិញ្ចើមធ្វើពើ៖
«អស្ចារ្យ! ទើបតែដឹងថាមានគេចាត់ទុកពៅបញ្ញាជាស្រីស្អាត?»
រិទ្ធិទំនងដឹងខ្លួនថាគេឌឺ អ្នកប្ដូរទឹកមុខស្មើព្រោះខ្លាចយុត្តនាចាប់ថ្នាក់បានពីចិត្ត ស្នេហារបស់គេចំពោះធីតាអ្នកច្បាប់។ គេនិយាយបន្តប់៖
«សម្រាប់ខ្ញុំ មនុស្សស្រីឲ្យតែកតញ្ញូ សុភាពរាបសារ ចេះស្គាល់ចាស់ទុំមិនធ្វើបាបអ្នកណា ខ្ញុំទុកថាជាស្រីស្អាតហើយ!.....ធម្មតា!!!»

យុត្តនាសើចចុងមាត់ គេបើកគ្របកក្អែកសម្លឹងមកមុខគូសន្ទនាហើយនិយាយចំៗ៖
«ប្រយ័ត្នក្លាយជាអ្នកស៊ើបចាញ់ស្នេហ៍ចុះចូលនឹងសត្រូវដោយសារលង់ស្រលាញ់ព្រះនាងម្ចាស់នៃព្រះនគរខ្មាំង!»
រិទ្ធិញញឹមស្ងួតមិនប្រកែកតែជាសញ្ញាថាមិនខ្វល់នឹងសម្តី បញ្ឆិតបញ្ឆៀងនេះទេ។ យុត្តនាមិនឲ្យនាយគេចបានងាយឡើយគេនិយាយមកបន្ថែម៖
«ពេលរិទ្ធិឯងមកប្រាប់ខ្ញុំពីរឿង Johanខ្ញុំគិតថាមានរឿងពីរ ទីមួយតើឯងពិតជាចង់ឲ្យខ្ញុំបានឱកាសធ្វើបាបចិត្តស្រីនោះ ឬក៏ឯងចង់ជួយនាង!»
រិទ្ធិញាក់ស្មា៖
«ឯងគិតយ៉ាងម៉េចក៏បានដែរ!»
យុត្តនាសើចខឹ។
រិទ្ធិធ្វើមុខស្មើនិយាយបកស្រាយបន្ថែម៖
«ប៉ាគិតថាឲ្យ ប៉ែន ពេជ្រប្រាថ្នា ចាត់ការឪពុកគេ ឧកញ៉ា ប៉ែន ពេជ្រ ទាល់ច្រកនឹងបញ្ចេញគម្រោងធុរកិច្ចនោះមក ប៉ុន្តែខ្ញុំមិនគិតអញ្ចឹងបានជាខ្ញុំមករកឯងឲ្យស្រោចស្រង់ ស្ថានការណ៍»
«ម៉េចក៏ឯងជឿថា តានោះមិនយកគម្រោងការនោះមកលក់ឲ្យប៉ា?»
«ដូចឯងនិយាយខាងដើមហើយ! បើរបស់នោះពិតជាអច្ឆរិយមែនតើគាត់ចាំបាច់អីទៅចំណាយកម្លាំង ជាមួយProjectថ្មីឲ្យគេបោកធ្វើអ្វី?»
«អញ្ចឹងប្រើពេលនេះឲ្យគាត់ជាប់គុកមិនល្អ? ឯងចាំបាច់អីមករកខ្ញុំឲ្យជួយគាត់!»យុត្តនាផ្ទាន់។
«ក្រែងឯងចង់រកឱកាសធ្វើបាបពៅបញ្ញាមិនអញ្ចឹង? ចង់មើលល្ខោនល្អមើលនៅពេលចុងក្រោយមិនមែនកណ្តាលទីទេ? ខ្ញុំទៅនៅបម្រើគេយូរយ៉ាងនេះ មកវិញដៃទទេមិនខាតស្លាប់ហើយ!»

យុត្តនាសម្លឹងមុខត្រជាក់ល្ហឹមរបស់រិទ្ធិ គេសួរវិញមួយៗ៖
«បើមិនជឿថាតានោះមានគម្រោងរតនៈសោភ័ណ ឯងតស៊ូធ្វើការឲ្យគេអីយូរម្លេះ?»
រិទ្ធិមិនឆ្លើយគេលើកកែវទឹកក្រេប។ យុត្តនាសញ្ជឹងគិត។ ឬមួយរិទ្ធិពិតជាមានបំណងផ្សេង? គេស្រលាញ់ពុកធម៌គេណាស់ គេទន់ភ្លន់តែម៉ឺងម៉ាត់ ធ្វើអ្វីក៏ច្បាស់អ្វីក៏មានគម្រោង ឬមួយគេ

ពិតជាមិនត្រឹមតែចង់បានរបស់នោះមកឲ្យពុកធម៌ថែមទាំង ចង់ធ្វើបាបកូនស្រីសំណព្វរបស់បុរសនោះដោយមធ្យោបាយត្រជាក់?

យុត្តនាលើកពែងកាហ្វេមកក្រេបមុនពេលហើបមាត់សួរត្រង់ៗ៖

«ឯងឲ្យខ្ញុំទៅជួយនាង យកឱកាសធ្វើបាបនាង! ផ្លូវចិត្តនាងទន់ខ្សោយ ឯងនឹងអាលយកបេះដូងនាង ក្នុងនាមសុភាពបុរស! ចុងក្រោយកូនពៅបណ្ដូលចិត្តរបស់តានោះត្រូវឈឺស្ទើរស្លាប់ដោយសារ ស្នេហាបេះដូងត្រជាក់របស់ឯង?»

រិទ្ធិអស់សំណើចពេលដែលយុត្តនានៅតែមិនចោលចរិតដែលគិតយ៉ាងណានិយាយយ៉ាងនោះ។

គេញាក់ស្មាគ្មានយោបល់។

យុត្តនាបន្តរភ្នែកចុះឡើងគិត។ ដល់វេនរិទ្ធិសើចស្ងើៗម្ដង៖

«ឯងច្រណែនខ្ញុំ?....ឬក៏អាណិតគេ?....»

យុត្តនាដាក់ពែងកាហ្វេចុះ គេពេបមាត់ចំអក ហើយផ្អែកខ្នងទៅនឹងបង្អែកកៅអីដោយចាប់ផ្ដើមហួច ធ្វើវាហី.....

បានគេងាកមុខចេញ រិទ្ធិធូរទ្រូងពីភាពតឹងតែងដែលខំរក្សាទឹកមុខ។

«ឯងគិតខុសហើយយុត្តនា! ពីមុនមែន! ដែលយើងស្អប់គេព្រោះការធ្វើបាបប៉ាធម៌យើង....តែនៅជាមួយគេយូរៗ ទៅ គឺយើងស្រលាញ់គេ ទាំងឪពុកទាំងកូនព្រោះគេស្រលាញ់យើង....ហើយគេពិតជាល្អចំពោះយើង មែន! ប្រការដែលយើងពិបាកចិត្តគឺកាលដែលទទួលយកការពិតពីភាពអកតញ្ញូ របស់យើងខ្លួនឯង!....យើងមិនមែនបេះដូងត្រជាក់ទេ....យើងមានចិត្តស្មោះ បេះដូងយើងឲ្យពៅបញ្ញាតាំងពីថ្ងៃនោះ....គឺថ្ងៃដែលគេប៉ះសាច់យើង ហើយលាបរបួសឲ្យយើង!»

អ្នកប្រុសទីពីរលើកកំភួនដៃដែលរលុបស្នាមរបួសអស់ទៅហើយតែវានៅបន្សល់ទុកស្រមោលស្នេហ៍ដ៏ជ្រៅមួយ....

គេកំពុងលង់ទៅក្នុងសេរីភាពនៃការអណ្ដែតអណ្ដូងរបស់ខ្លួនឯង ស្រាប់តែឃើញយុត្តនាញាក់ចិញ្ចើមដាក់ហើយស៊ីញ៉ូគេឲ្យបែរក្រោយ។

«ផែនដីនេះតូចមែន!»

អ្នកប្រុសទីមួយនិយាយទាំងទឹកមុខជិនឆ្អន់ហើយគេឱនទៅផឹកកាហ្វេ ងាកគេចចេញក្នុង

កិរិយាមិនចូលចិត្ត។ សកម្មភាពនេះធ្វើឲ្យរិទ្ធិដឹងថាអ្នកណាម្នាក់កំពុងនៅពីក្រោយខ្នង នាយពិតណាស់។ភ្លាមនោះនាយបើកភ្នែកធំៗព្រោះនឹកឃើញដល់ ពៅបញ្ញា?«ម៉េចនឹងអាចឲ្យនាងឃើញយើងនៅជាមួយយុត្តនាកើត?»
គេបែរក្រោយយឺតៗក្នុងពេលបេះដូងលោតញាប់ជាងមុន។
តាមប្រលោះកញ្ចក់រនាំង គេសម្លឹងទៅក្នុងជួរដ៏វែងដែលមនុស្សម្នាកំពុងតម្រង់សម្រាប់ រង់ចាំដល់វេនទិញកាហ្វេ ពន្លឺភ្នែកគេបញ្ឈប់ត្រឹមស្រីស្អាតដ៏ស៊ីវិល័យមួយរូបក្នុងឈុត ពណ៌ស។ សំពត់ខ្លីខើចរបស់នាងបង្ហាញទម្រង់សមឥតទាស់នៃកំភួនជើងហាប់ណែន តែរលូនស្រមោចវារជ្រុះ។
«អ្នកនាងធំ?»
ប៉ែន ពេជ្រអមរា កូនស្រីច្បងនៃភរិយាដើមត្រកូល ប៉ែន ពេជ្រ ជាកូនភ្លោះជាមួយ ប៉ែន ពេជ្រប្រាថ្នា ហើយដែលមិនដែលដឹងទេថាឪពុកបង្កើតរបស់នាងតាមពិតគឺជាបុរសអ្នក លេងឥណទានដ៏ស្មុកស្មាញគឺ អគ្គទេសាភិបាល ហួត ស៊ីវ។

នាងដឹងត្រឹមថា នាងជាកូនស្រីច្បងរបស់ឧកញ៉ា ប៉ែន ពេជ្រ ដែលចុងក្រោយស្នេហារវាងឪពុកនិងកូនរបស់នាងត្រូវបានបំផ្លាញដោយសារ ការចាប់កំណើតនៃបុត្រីពៅខាងប្រពន្ធចុង ប៉ែន ពៅបញ្ញា។
ក្នុងអាកប្បកិរិយាជាអភិជន នារីនោះងើយមើលលើមិនបានរវល់នឹងមនុស្សជុំវិញខ្លួនទេ។ នាងទ្រកាបូបដៃពណ៌ទឹកក្រូចដ៏ធ្ងន់និងមានតម្លៃ ហើយបង្ហាញភាពធុញថប់ជាមួយការរង់ចាំនេះ។
«ដល់ពេលឯងសម្តែងជាចៅចិត្រទៀតហើយរិទ្ធិ! មិនរំខានឯងទេ! មួយពេលនេះឲ្យឯងប្រើកាតឯងទៅចុះ!»
យុត្តនានិយាយខ្ញីហើយក្រោកចេញវឹងតាមទ្វារក្រោយគេច កុំឲ្យសមាសភាពរបស់រិទ្ធិត្រូវគេឃើញនៅជាមួយនាយនាំតែផ្ទុះ ការសង្ស័យ។
រិទ្ធិរៀបចំខោអាវស្រួលបួលហើយក្រោកចាកចេញពីទីអង្គុយតម្រង់ទៅរកស្រីស្រស់។ មកដល់ប្រមាណ៣ម៉ែត្រពីនាង អមរាងាកមករកនាយ។ នាងញញឹមលុបចោលភាពធុញថប់ ហើយឧទានតិចៗក្នុងសភាពធីតាត្រកូលខ្ពស់៖
«ជំនួយការរិទ្ធិ?»

រិទ្ធិញញឹមឱនលំទោនក្នុងភាពជាអ្នកបម្រើឪពុកនាងស្រាប់ទៅហើយ។
«អ្នកនាងអញ្ជើញអង្គុយសិនបានទេ!ទុកខ្ញុំជាអ្នកឈររង់ចាំទិញជូន!»
ស្រីស្អាតហាក់ពេញចិត្តនឹងការផ្ដាប់បម្រើដោយហេតុថាស្បែកជើង កែងនាងខ្ពស់ហួសកម្លាំងដែលនាងអាចទប់ជំហរបានយូរ។ នាងញញឹមជាកិច្ចអរគុណ៖
«សំណាងណាស់បានជួបលោកនៅទីនេះ! អរគុណណ៎ា!»
នាងចាកចេញពីជួរក្នុងពេលបុរសឱនគោរពហើយចូលទៅជំនួសនាង។ ស្រីស្អាតអង្គុយរង់ចាំបានបន្តិចបុរសក៏បានកាហ្វេមកមែន។
«លោកអង្គុយលេងសិនបានទេនឹងអាលខ្ញុំបានសួរនាំរឿងលោកប៉ាផង!!»
«បាទ!»
អ្នកប្រុសទីពីរដាក់បង្គុយនៅពីមុខស្រីស្អាត។ អមរាមិនមែនមិនដឹងថាបុរសនៅពីមុខខ្លួននេះសង្ហាប្លែកខុសពី ប៉ុន្មានឆ្នាំមុននោះទេ។ ដូចពាក្យគេថាបុរសកាន់តែចាស់កាន់តែសង្ហានោះអមរាហាក់ស្រេកឃ្លានក្នុងការលបមើលស្នាទាំងគូដ៏ធំមាំរបស់នាយ។
«លោកប៉ាមានរឿង ខ្ញុំនៅជប៉ុន! លោកដឹងដែរមែនទេ ខ្ញុំជាប់រវល់ក្នុងវគ្គសាឡន! ខ្ញុំត្រៀមបើកសេវាកម្មនេះ! បានជារវល់រៀនរហូតដល់ទើបនឹងដឹងរឿងនេះក្រោយគេ! និយាយរួមទាល់តែសក្ខណា ខលមកពីអាមេរិកបានខ្ញុំដឹង!»
«លោកដោះស្រាយបានហើយ! សុខភាពក៏ល្អជាងមុន!»
«ខ្ញុំមកដល់ភ្នំពេញយប់មិញ! ព្រឹកនេះថាទិញកាហ្វេហើយទៅផ្ទះនោះមើលលោកប៉ា! យើងទៅជាមួយគ្នាទៅបើលោកមិនយល់ទាស់!»
«បាទ! ខ្ញុំត្រូវទៅទីនោះស្រាប់ហើយ!»
«អញ្ចឹងខ្ញុំទៅជាមួយលោក! ខ្ញុំប្រាប់ឲ្យសូហ្វ័រចេញឡានចាំ! យើងទៅតែម្ដងទៅកុំឲ្យខាតការងារលោក!»
«បើមិនយល់ទាស់ទេអ្នកនាងទៅឡានជាមួយខ្ញុំតែម្ដងក៏បាន! ជាឡានលោកឧកញ៉ាសម្រាប់ជូនអ្នកនាងពៅបញ្ញាដែរ!»
ការស្នើសុំធ្វើខ្លួនសូហ្វ័ររបស់បុរសសង្ហាសមភ្នែកអាចធ្វើឲ្យ នាងរីករាយ តែស្រីស្អាតរុះរោយពន្លឺភ្នែកស្រស់ស្រាយពេលឮគេរំលឹកពីឈ្មោះ ប្អូនស្រីខុសម្ដាយ។ ទោះយ៉ាងណា តែនាងខំទប់មិនឲ្យនរៈសង្ហាដឹង។
ស្រីស្អាតញញឹមស្មើៗ៖

«ចាសបាន!»
គេនាំផ្លូវស្រីស្អាតមកដល់រថយន្តទំនើបហើយបើកទ្វារជូននាង។

គារវកិច្ចបុរសសង្ហានិងជានិស្សិតលេខមួយផ្នែកពាណិជ្ជកម្មនេះ បានធ្វើឲ្យអមរាលួចនឹកច្រណែនដល់វាសនារបស់ពៅបញ្ញាដែលបាននាយ នៅផ្គាប់បម្រើរាល់ថ្ងៃ។ ទោះយ៉ាងនោះក៏ដោយនារីអភិជនដែលមានម្ដាយជាខ្មែរាជវង្សពិតជាមិន ងាយបញ្ចេញការពិតមកលើកាយវិការនាងឡើយ។ នាងនៅតែមើលទៅស្រស់ស្រាយហើយស្លូតបូត។
រិទ្ធិបើកឡានជូននាងយឺតៗ ដោយមិនមានវាចាស្ដីតាមទម្លាប់អ្នកធ្វើការឲ្យគេ។
«ពៅបញ្ញាទៅរកលុយពីណាមកបានលឿនម្ល៉េះ?»នាងគិតម្នាក់ឯងស្ងាត់ៗ។
«ឬមួយលោកប៉ាពិតជាមានប្រាក់សល់ច្រើនយ៉ាងនេះនៅក្នុងគណនី? បើពុំនោះទេតើមុខបរជាមេធាវីរបស់នាងអាចរកលុយបានប៉ុន្មានទៅ ក្នុងមួយឆ្នាំៗ!»
នាងពេបមាត់ព្រោះមិនពេញចិត្តគ្រប់យ៉ាងទាក់ទងនឹងប្អូនស្រីម្នាក់ នេះ។ ប៉ុន្តែនាងប្រាកដណាស់គ្មានអ្នកណាមើលឃើញភាពទោមនស្សនឹងច្រណែន និន្ទារបស់នាងឡើយរួមទាំងបុរសសង្ហាដែលកំពុងបើកឡាននេះផង។
ប៉ែន ពេជ្រអមរា អាចបញ្ជាវាចាឲ្យផ្ទុយទៅនឹងការពិតបានយ៉ាងល្អ៖
«ថ្មើរណេះ ពៅនៅផ្ទះដែរ?»
រិទ្ធិដឹងថាបងប្អូនគេតែងទម្លាប់ហៅគ្នារបៀបនេះ។ នាយឆ្លើយរឹង៖
«បាទ! ព្រោះថាឧកញ៉ានៅសម្រាកផ្ទះនៅឡើយ! អ្នកនាងពៅនៅកំដរលោក!»
«ល្អតើ! ខានជួបស្រីពៅយូរហើយ! មានរបស់ផ្ញើពីជប៉ុនទៀត»

រថយន្តព្រហើនមួយបោលមកពីណាក៏មិនដឹងតម្រង់មកទាំងទទឹងទិសធ្វើឲ្យរិទ្ធិភ្ញាក់ក្រញាងងាកគេចចេញទាំងប្រធឹតប្រធើយ។
ទោះបីគេចផុតហើយតែរាងកាយស្រីស្អាតនៅពីក្រោយក៏ភ្លាត់ជំហរមក មុខពេញទំហឹងកល់មុខនាងទៅនឹងស្មារបស់នាយទើបអាចទប់ខ្លួនជាប់។
បុរសអ្នកបើកបរងើបមុខសម្លឹងម្ចាស់ឡាននោះទាំងកំហឹង....តែរំពេចនោះគេហួសចិត្តទៅវិញព្រោះគ្មានអ្នកណាក្រៅយុត្តនាទេ ។
អ្នកប្រុសទីមួយនៃលោកអគ្គទេសាភិបាល មិនត្រឹមមិនភ័យព្រួយនឹងឧប្បត្តិហេតុនេះគេថែមទាំងញាក់ចិញ្ចើម ខ្វាច់ដាក់ជំនួយការរិទ្ធិមុនពេលបោលឡានចេញទៅវ៉ាវផ្អើលអស់ អ្នកផង។

រិទ្ធិអស់ពីហួសចិត្ត គេទៅជាគ្រវីក្បាលតិចៗ...អ្នកដឹងថាយុត្តនាមិនចូលចិត្តកូនៗទាំង ៤ របស់ប៉ែនពេជ្រដូច្នេះគេរមាស់ចិត្ត ចង់អុកឡុកសូម្បីតែអ្នកនាងច្បងនេះឡើង។
គេងាកមុខវិញចំពេលស្រីស្អាតងើបមុខយឺតៗពីស្មាគេទាំង ស្លេកស្លាំង។ នាងទន់ភ្លន់ពេក ហើយ សំលៀកបំពាក់នាងរឹបពេកធ្វើឲ្យនាងប្រឹងងើបវិញដោយលំបាក ដូច្នេះបុរសត្រូវតែលូកដៃទៅជួយត្រកងនាង។ ស្រីស្អាតអង្គុយលើកន្លែងដើមវិញហើយក៏ពិតមែន តែនាយនៅតែមិនអស់ចិត្តស្ទុះចេញពីឡានបើកទ្វារខាងក្រោយជួយលើក កាបូបនាងរៀបរយនិងសួរនាំ៖
«អ្នកនាង! មានត្រូវត្រង់ណាទេ?»
តាមពិតបើជាអ្នកផ្សេងនាងមុខតែបន្ទោស តែនេះអមរានៅតែទន់ភ្លន់ព្រោះជាប់ចិត្តនឹងកំភួនដៃសង្ហាមាំមួនរបស់ គេដែលកាន់កំភួនដៃនាងជាប់។ នាងរវេរ្នែកសម្លឹងដៃអ្នកជំនួសចម្លើយធ្វើឲ្យរិទ្ធិភ្ញាក់ខ្លួនមក វិញថា ដោយសារបារម្ភពីនារីពេកនាយច្រឡំកាន់ដៃនាងពីពេលណាមកមិនដឹង ហើយកាន់មិនលែងទៀត។ គេដកដៃចេញវិញរឹង៖
«សុំទោស!»
ស្រីស្អាតក៏អៀនដែរ នាងបន្លប់៖
«អ្នកណាគេហ្នឹង? បើកឡានអាក្រក់ណាស់!»
រិទ្ធិមិននិយាយតែក្នុងចិត្តគេបន្ទោសស្ងាត់ៗ៖
«ជ្រុលពេកហើយយុត្តនា!»
ស្រីក្រមុំអភិជនរៀបចំអង្គុយសាជាថ្មី។ រិទ្ធិបិទទ្វារឡានឲ្យនាងវិញហើយឡើងមកបើកទៅមុខទៀត។
នាងចាប់អារម្មណ៍និងអ្នកបញ្ជាឡានដ៏យ៉ាប់នោះតិចតួចទេបើធៀបទៅ នឹងទំហំចិត្តញាប់ញ័រដែលត្រូវទង្គិចទៅរកបុរសសង្ហាពេញទំហឹង អំបាញ់មិញ។
នាងគិតម្នាក់ឯងក្នុងចិត្ត៖
«ម្នាក់នេះ ជាអ្នកធ្វើការឲ្យគេសោះអីក៏ឡូយម្ល៉ឹងៗ! គិតទៅព្រហ្មលិខិតលលេងមែន! បើគេសង្ហាយ៉ាងនេះ រៀនពូកែយ៉ាងនេះ ហើយជាកូនអ្នកខ្ពស់ទៀត ប្រាកដជាសម្លាប់ចិត្តស្រីៗរយនាក់ហើយ!»

...រថយន្តលូនចូលក្នុងបរិវេណភូមិគ្រឹះប៉ែនពេជ្រដែលចាប់តាំងពី គាត់លះលែងជាមួយភរិយាទីមួយជាង១០ឆ្នាំមកនេះ គាត់បានធ្វើឲ្យផ្ទះទីពីរនោះត្រូវបានអ្នកមុខអ្នកការនានា

ស្គាល់ ថាជាលំនៅឋានជាអចិន្ត្រៃយ៍របស់ខ្លួន។ ជាសំណូមពររបស់ភរិយាដើមដែលចង់បានកូនទាំងបីនៅក្បែរនោះ ប៉ែន ពេជ្រប្រាថ្នា ប៉ែន ពេជ្រអមរា និងកូនស្រីពៅដែលនៅសិក្សានៅបរទេសនៅឡើយគឺ ប៉ែន ពេជ្រសក្ខណា មិនដែលឈានមកកាន់ទីនេះសូម្បីតែមួយជំហានឡើយ។

«អ្នកនាង...អញ្ជើញ!»

រិទ្ធិបើកទ្វារទទួលនារីអភិជនហើយអមនាងធ្វើដំណើរទៅកាន់បន្ទប់ ទទួលភ្ញៀវធំល្វឹង ដែលទុកសម្រាប់ទទួលតែអ្នកមុខអ្នកការតែប៉ុណ្ណោះ។

«ខ្ញុំចង់ឡើងទៅបន្ទប់លោកប៉ាតែម្តង!»នាងនិយាយតិចៗដោយឱនដោះស្បែកជើងកែងផង។

«អ្នកបង?»

សូរសព្ទស្រាលៗលាន់មកពីលើជណ្តើរធ្វើឲ្យអមរាងើបមុខទាំងមិនទាន់ដោះស្បែកជើងរួច។ នោះគឺមេធាវី ប៉ែន ពៅបញ្ញា ដែលនាងធ្លាប់តែឃើញតាមទស្សនាវដ្តីតែប៉ុណ្ណោះក្នុងរវាងពេលប៉ុន្មានឆ្នាំមកនេះ។

ស្រីតូចនៃផ្ទះឧកញ៉ាប៉ែនពេជ្របោះជំហានចុះមកថ្នមៗទាំងស្នាមញញឹម ទទួលស្រីជាបងខុសម្តាយ។ បបូរមាត់អមរាញញឹមទៅរកនាង តែក្នុងបេះដូងនាង គឺទាក់ទាមដោយបន្លាម្យ៉ាង។

ឃើញពៅបញ្ញានាងក៏នឹកឃើញដល់គ្រាមួយដែលម្តាយនាងប្រាប់ថា លោកប៉ាមានស្រីថ្មីហើយ។គាត់លបលួចមានកូនឥតខាន់ស្លាម្នាក់ហើយ ទីបំផុតគឺបញ្ចប់ក្តីសង្ឃឹមរបស់គ្រួសារនាងដោយការលែងលះ។

អមរាក្រវែ្នកសម្លឹងរាងកាយនារីមេធាវីពីលើដល់ក្រោម ប៉ុន្តែមិនបានបញ្ចេញភាពមិនពេញចិត្តក្នុងក្រសែភ្នែកនាងឡើយ។

នាងប្រាប់ខ្លួនឯងស្ងាត់ៗ៖

«ពៅបញ្ញា! ទុកថាទេវតានៅមានយុត្តិធម៌សម្រាប់យើងខ្លះដែរ ដែលឲ្យឯងមានរូបរាងអន់ថយយ៉ាងនេះ! ឯងនៅក្មេងសោះតែមើលទៅគឺសមតែយើងទេដែលហៅឯងថាអ្នកបង!»

ជានារីដែលចាប់អារម្មណ៍លើរូបសម្ផស្សនិងជាអនាគតអគ្គនាយកក្រុមហ៊ុន ថៃសម្រស់ស្រាប់ទៅហើយ អមរាមុខតែឈឺចិត្តប្រសិនបើនាងឃើញថាពៅបញ្ញាមានរូបឆោមលោមពណ៌ ល្អជាងនេះ តែពេលជួបគ្នាតទល់នាងហាក់ស្ងប់ចិត្តវិញព្រោះថា ស្រីអភិជនតូចដែលមានសម្បុរ

ស្រងាំធ្វើម៉េចអាចដណ្ដើមតំណែងជាស្រី ស្អាតបំផុតក្នុងគ្រួសារ ប៉ែន ពេជ្រ ពីនាងបានទៅ។ នាងមិនបានដឹងទេថាឈាមរបស់នាងពាក់កណ្ដាលជារបស់បុរសកូនកាត់ ចិន ហួត ស៊ីវ ហើយត្រកូល ប៉ែន ពេជ្រ ដែលនាងប្រើ គឺខ្ទីអតីតកាលនៃចំណងអាពាហ៍ពិពាហ៍បង្ខំចិត្តមកប្រើតែប៉ុណ្ណោះ។

## ៩

«មនុស្សកំព្រាចិត្ត»

«ឯងកំព្រាដូចតែគ្នាដែរហ្នឹង!»
គេនិយាយតិចៗទៅកាន់ ដួងខែភ្លឺស្រទន់ ។ បុរសមាត់ឆៅចិត្តក្ដៅកំពុងសង្កត់ចិត្តខ្លួនជាមួយភាពត្រជាក់ ផ្អែមនៃកែវបីយ៉ែរពុះខ្ទោលភ្នែកគេសម្លឹងទៅលំហមេឃ ។

បុរសកំព្រា តែងទម្លាប់ផឹកម្នាក់ឯង…ស្រវឹងម្នាក់ឯងហើយ ក៏ដេកលង់លក់ម្នាក់ឯងនៅទីនេះ។

….នៅក្នុងសុបិន….
«សន្យានឹងម៉ាក់!….ត្រូវថែខ្លួន! ប៉ាធម៌ជាអ្នកមានគុណមើលថែគ្រួសារយើងរហូតមក…គាត់ក៏ជា មិត្តល្អរបស់ពុកកូន….ថ្ងៃក្រោយ…ពេលគាត់ឲ្យធ្វើអ្វីកូនកុំ ជំទាស់!….មួយទៀតរឿងរ៉ាវជាមួយផ្ទះប៉ែនពេជ្រជារឿងអតីតកាលឈប់រំលឹក មកធ្វើបាបខ្លួនឯងទៅយុត្តនា!»
គេរវើរវាយនិយាយរអេះរអុះតែម្នាក់ឯង៖
«ម៉ាក់! ហេតុអ្វីម៉ាក់ឆាប់ទៅ! ម៉ាក់ទុកឲ្យខ្ញុំនៅឯកោម្នាក់ឯង?»
គេរអ៊ូរហូតដល់ដឹងខ្លួនហើយភ្ញាក់មកវិញឃើញខ្លួនឯងដេកផ្ងារលើប៉ោអ៊ីក្រោមលំហមេឃ។
…គេរភ្នែកដែលក្រហមដោយភាពងោកងុយសម្លឹងទៅកែវបីយ៉ែរ….បន្ទាប់មកកូនផ្ទះតូចដែលនៅពីក្រោយខ្នង។
យុត្តនាធ្មេចទៅវិញបន្តិចទើបបើកភ្នែកសាជាថ្មី ហើយច្រត់ដៃក្រោក។
អ្នកប្រុសធំនៃអគ្គទេសាភិបាលដ៏មានស្ដុកស្ដម្ភផុតគេក្នុងមជ្ឈដ្ឋាន ធុរកិច្ចជនកម្ពុជា ដើរសំដៅទៅរានហាលហើយសម្លឹងទៅថ្នល់ខាងក្រោម។
តំបន់នេះម៉េចនិងស្រស់ត្រកាលប្រៀបដូច Apartment Campu House នៅសង្កាត់បឹង

កេងកងទៅ។នឹកឃើញដល់រឿងនេះអ្នកនឹកឃើញដល់ស្រី ម្នាក់ ដែលប៉ុន្មានថ្ងៃមុននេះត្រូវអ្នកបង្ខំឲ្យទៅជួបទាំងទទឹងទិស។

យុត្តនាញញឹមចុងមាត់....គេឱនទៅលូកយកទូរសព្ទក្បែរកែវប៊ីយែរមកគ្រវីហើយពីរបីវិនាទីប៉ុណ្ណោះគេសម្រេចចិត្តចុចវា....

ស្នូរទូរសព្ទលាន់ឡើងពុះជ្រែកភាពស្ងប់ស្ងាត់នៃរាត្រីកាល.....

មេធាវីស្រីវ័យក្មេងភ្ញាក់ឃឹតៗពីដំណេក....

....នាងរាវដៃស្រវារកទូរសព្ទដោយមិនបើកភ្នែក....

«អ្នកណាមានរឿងអីកណ្ដាលយប់?»ពៅបញ្ញារអ៊ូតិចៗ។

ពៅបញ្ញាបើកភ្នែកព្រឹមៗឃើញលេខមិនស្គាល់បម្រុងចុចចោលមិន ទទួលទៅហើយ តែមិនដឹងយ៉ាងម៉េចនាងចុចខុសទៅចំប៊ូតុងទទួលទៅវិញ។

ជ្រុលទៅហើយក៏និយាយខ្សាវៗ៖

«ចាំ!»

ស្ងាត់ច្រៀបគ្មានអ្នកឆ្លើយតបមកវិញ ប៉ុន្តែមានសញ្ញាទទួល។

ពៅបញ្ញាងងុយផងមិនច្បាស់លាស់ក្នុងអារម្មណ៍ផង នាងនិយាយសាជាថ្មី៖

«អាឡូ!»

នៅតែស្ងាត់ច្រៀប។ នាងខ្ទប់មាត់ស្ងាបហើយទើបនិយាយ៖

«អត់និយាយ! ខ្ញុំបិទហើយណ៎ា!»

បុរសឯកោដែលសំងំចាំស្ដាប់សំឡេងនាងដល់ទៅបីសាដាច់ចិត្តឆ្លើយតប៖

«ហើយបិទហ្នឹង គេមិនចេះ Callទៅទៀតទេ?»

ត្របកភ្នែកពៅបញ្ញាបើកភ្លែតជាមួយភាពភ្ញាក់ផ្អើល។

«យុត្តនា?»

នាងភ្លាត់មាត់ខ្សាវៗស្ទើរមិនចង់ឮ។

នាងរេភ្នែកសម្លឹងនាឡិកានៅចុងជើង........ម៉ោងមួយរំលងអធ្រាត្រ ហើយ......។ ស្រីតូចរេគ្រាប់ភ្នែកចុះឡើងដោយភិតភ័យផងងឿងឆ្ងល់ផង។ នៅពេលនាងស្ងាត់មាត់ដូចគេចុក ដល់វេនបុរសនោះសើចកខឹកមកពីចុងម្ខាង។

...ច្បាស់ណាស់គឺគេ....។

«រឿងគ្មានសុជីវធម៌ថ្នាក់នេះក៏គេធ្វើទៅកើតដែរ....»នាងគិតទាំងជ្រួញចិញ្ចើម។
គេចុចមកហើយមិននិយាយអ្វីមានតែសើចដៀមដាមនាង....ពៅបញ្ញាសួរវិញភ្លាម៖
«លោកមានការអី?»
«នឹកនាងហ្នឹងហើយ!!»
ស្រីក្រមុំតប់ប្រមល់នឹងរងសម្ពាធស្រេចទៅហើយរាល់ពេលដែលឮសំឡេងគេ កុំថាឡើយមកទ្រាំស្ដាប់គេនិយាយគ្មានន័យខ្លឹមសារបែបនេះទៀត។ នាងនៅស្ងៀមមិនដឹងត្រូវធ្វើយ៉ាងណាស្រាប់តែគេបន្ត៖
«អរហ្អី? កុំយល់ច្រឡំ មិនមែននឹកស្រលាញ់ទេ ឈប់ដេកយល់សប្ដិទៅ! »
«និយាយអស់ចិត្តហើយមែនអត់!....អញ្ចឹងទេ ខ្ញុំដាក់ទូរសព្ទវិញបានឬនៅ?»នាងតបទាំងខឹងព្រោះតែទប់ចិត្តទ្រាំ ស្ដាប់សម្ដីគ្មានក្បាលកន្ទុយនេះមិនបាន។
«មិនសប្បាយចិត្ត? មិនសប្បាយចិត្តក៏ត្រូវស្ដាប់ដែរ! ថាមិនបានខ្ញុំដូរចិត្ត ឲ្យនាងចេញមកជួបឥឡូវនេះផងពៅបញ្ញា!»

ស្រីស្អាតផ្លាស់ទឹកមុខទៅជាស្លេក។ សម្ដីបុរសនោះកាលពីនៅបន្ទប់ជាន់ទី៦របស់គេលាន់មកវិញក្នុង អារម្មណ៍ចងចាំរបស់នាង៖
«ខ្ញុំឲ្យនាងជំពាក់! ថ្ងៃក្រោយត្រៀមខ្លួនឲ្យស្រួលផង!»
នាងរវើកវិរះគិតស្វាងអស់ភាពងោកងុយ។ ឃើញនាងគ្មានពាក្យនឹងឆ្លើយសូម្បីមួយម៉ាត់យុត្តនាហៅនាងស្រាលៗ៖
«ពៅបញ្ញា!»
«ចាស?»
ម៉េចក៏ឯងឆ្លើយនឹងគេលឿនដល់ម្ល៉ឹង?
....មិនទាន់អីផងឯងចាញ់សម្លុតគេទៅហើយ? មនុស្សនេះមិនមែនគួរឲ្យខ្លាចទេតែគួរឲ្យស្អប់ត្រូវជាង! ឯងឈរលើសវនាការរាប់មិនអស់មិនខ្លាចអ្វីគ្រប់យ៉ាងមកខ្លាចអី ប្រុសអ្នកលេងគ្មានការអប់រំម្នាក់?
នាងគិតទាំងបន្ទោសខ្លួនឯង។
«លោកចង់បានអីនិយាយឲ្យឆាប់មក!»នាងនិយាយទាំងមួម៉ៅក្អឹកក្អក់។
តែបុរសមិនខឹងតប គេបែរជាសើច៖

«នាងកាន់តែអន្ទះសាខ្ញុំកាន់តែពន្យារពេលពៅបញ្ញា!»
«ខ្ញុំមិនយល់ពីលោកទេយុត្តនា? មនុស្សដូចលោក...»មិនដឹងគិតឃើញយ៉ាងម៉េចទេនាងបញ្ឈប់សម្ដីកណ្ដាលទី។
«នាងមិនបាច់យល់ពីខ្ញុំទេមេធាវី! នាងគ្រាន់តែដឹងថា នាងគេចខ្ញុំមិនបានទៅបានហើយ!»
ស្រីស្អាតនៅទ្រឹងព្រោះមិនដឹងថាត្រូវប្រឈមបែបណាជាមួយបុរសដែល នាងទុកថាមានពោគចិត្តនេះ។ សំខាន់គឺនាងមានចំណុចខ្សោយក្នុងដៃនាយ។ រឿងបងប្រុសនាងនិងរឿងប្រាក់១១លានថាមិនធំក៏មិនតូចដែរ។ លោតែថ្ងៃណាមួយម្នាក់នេះឆ្កួតចិត្ត យករឿងពិតបង្ហាញប៉ូលិស អ្នកដែលធ្លាក់ខ្លួនឈឺសាជាថ្មីគឺលោកប៉ានាង ហើយអ្នកដែលត្រូវចូលពន្ធនាគារគឺបងប្រុសនាង។
ឃើញនាងនៅស្ងៀមគេក៏កាន់តែបានចិត្ត។
«រាត្រីសួស្ដីមេធាវី!»
គេបិទទូរសព្ទដោយមិនចាំបាច់ស្ដាប់សូម្បីតែពាក្យលា។

គេទៅបាត់ហើយ។
បរិយាកាសធូរស្រាលមកវិញបន្តិច តែនាងក៏លែងងោកងុយហើយដែរ។ ភាពនឿយហត់មួយរយៈនេះនិងស្ថានភាពធូរស្រាលក្នុងគ្រួសារក្នុងពេល ចុងក្រោយនេះ អាចជួយឲ្យពៅបញ្ញាលង់លក់ស្កប់ស្កល់ជាលើកដំបូង មិនស្មានថាដំណេកនេះត្រូវបានបំផ្លាញដោយការសន្ទនាតាមទូរសព្ទគ្មាន ខ្លឹមសាររបស់គេ។
ទោះយ៉ាងណាវាក៏មានប្រយោជន៍ឲ្យពៅបញ្ញារំលឹកមកវិញនូវហេតុការណ៍ដែលនាងបានប៉ះទង្គិចជាមួយគេនៅឯសង្កាត់បឹងកេងកង។
នារីអភិជននឹកឃើញដល់ពាក្យសម្ដីឌឺដងទាំងឡាយ ហើយនឹងម្រាមដៃព្រហើនរបស់គេដែលលូកមកបង្ខំឱបនាងហើយថើបបបូរមាត់ នាង។
ពេលដែលនាងប្រើស្បែកជើងកែងជាន់ជើងគេដើម្បីការពារខ្លួនហើយរត់ ចេញ គេផ្ទុះកំហឹងទាញអាវនាងមកវិញរហូតដល់របូតមួយចំហៀងស្មា។
ស្រីអ្នកច្បាប់ដៀងភ្នែកមើលខ្លួនឯងក្នុងផ្ទាំងកញ្ចក់។ នាងមិនចាប់អារម្មណ៍និងសាច់ស្មាសខ្ចីដែលឆ្លុះជាមួយអាវដំណេកពណ៌ ចុងឈូកនោះទេ ប៉ុន្តែគឺស្នាមអ្វីមួយលើស្មានោះ ដែលធ្វើឲ្យនាងរភ្នែកត្រិះរិះ។

«គេឃើញស្នាមនេះ!...គេនឹកដល់រឿងចាស់...ហើយគេក៏ស្រន់កំហឹង?»
នាងគិតបណ្ដើរប្រើម្រាមដៃអង្អែលស្នាមក្រហមទំហំប៉ុនពីរថ្នាប់ដៃ ដែលផុសលើស្មាប្រៀបបី ដូចជាស្លាកស្នាមបន្សល់ពីរបួសអ្វីមួយ។ ទោះបីវាជាសះ តែស្នាមរបួសនៅតែបន្សល់ទុក។ ....ជួនកាលនាងមិនស្មានដល់ទេថា បុរសកំព្រានៅឯជាន់ទីបួនផ្ទះចាស់សេសសល់តាំងពីជំនាន់បារាំងឯណោះ ក៏កំពុងនឹកគិតដល់ស្លាកស្នាមនោះដូចគ្នា....

«ពូពេជ្រជាអ្នកសម្លាប់ប៉ាខ្ញុំ!»ក្មេងប្រុសឈ្មោះយុត្តនា ស្រែកប្រាប់ប៉ូលិសហើយយំគគ្រុក។ ប៉ូលិសមើលតាមចង្អុលដៃគេឃើញបុរសអ្នកជំនួញ ប៉ែន ពេជ្រ កំពុងឈរទ្រឹងសម្លឹងសាកសពមិត្តម្នាក់ក្នុងចំណោមបួននាក់របស់ ខ្លួន ដែលដេកស្លាប់ម្នាក់ឯងលើផ្ទះតូចកម្ពស់នៅជាន់ទីបួនក្នុង សង្កាត់ដ៏ក្រីក្រនេះ។
«គាត់សម្លាប់ប៉ាខ្ញុំ! ពេលជូនខ្ញុំទៅសាលាប៉ាប្រាប់ថាត្រលប់មកវិញជួបពូពេជ្រ ហើយកាលពីយប់មិញគាត់ឈ្លោះជាមួយពូពេជ្រ»
ប៉ែនពេជ្រ នៅតែមិនប្រកែក។ គាត់ប្រហែលជាគិតថា នេះជាការភ័ន្តច្រឡំរបស់ក្មេងប្រុសតូចម្នាក់ ។គាត់ក៏ប្រហែលមិនដឹងទេថា វាអាចក្លាយមកជាគំនុំសូម្បីតែពេលវេលាហួសមកជាងម្ភៃឆ្នាំហើយ ក្ដី។
យុត្តនាបិទភ្នែកដែលក្រហមដូចភ្លើង តែចិត្តគេនៅតែរត់ចុះឡើងជុំវិញភាពមិនអស់ចិត្តៈ
«ម៉ាក់! ប៉ាស្លាប់ដោយអយុត្តិធម៌! ឃាតករួចខ្លួន តែម៉ាក់មិនឲ្យកូនសងសឹក តើហេតុអី?»
នឹកឃើញសាជាថ្មីដល់ពេលមួយ...នៅមុខគេហដ្ឋានដ៏ធំរបស់អ្នកជំនួញ ប៉ែន ពេជ្រ ដែលកន្លងមកគេតែងចុះឡើងលេងជាមួយកូនស្រីពៅផ្ទះនេះ បង្រៀនគណិតវិទ្យានាង ហើយដាំផ្កាក្នុងសួនជាមួយនាង ឲ្យចំណីត្រីក្នុងផើងជាមួយគ្នា។

បន្ទាប់ពីឪពុកស្លាប់ កុមារាយុត្តនាមិនដែលទៅទីនេះទៀតទេ គេត្រូវបានមិត្តម្នាក់ទៀតរបស់ឪពុកគឺហួត ស៊ីវ មកជួបញឹកញាប់ហើយជារឿយៗមានតែបុរសនោះប៉ុណ្ណោះ ដែលព្រមស្របនឹងសម្ដី
គេគាំទ្រគេថា ប៉ែន ពេជ្រ ពិតជាសម្លាប់ឪពុកគេ។
ថ្ងៃនោះម្ដាយគេបានស្គាត់ជួប ប៉ែន ពេជ្រ ជាមិត្តចាស់របស់ប្ដី ព្រោះតែម្យ៉ាងប៉ុណ្ណោះគឺចង់ផ្ញើកូនប្រុសនៅនឹងគាត់ព្រោះនាងឈឺ ធ្ងន់។
«កូនមិនទៅទេ! កូនមិននៅទីនេះ!»

«ក្មួយយុត្តនា! ក្មួយស្តាប់ម្តាយនៅទីនេះជាមួយពូ! លេងជាមួយបញ្ញា រៀនជាមួយគ្នាណ៎ា»
«អត់ទេ! ពូពេជ្រជាមនុស្សអាក្រក់! ពូពេជ្រជាឃាតកសម្លាប់ប៉ា»
ក្មេងប្រុសដែលពេញដោយគំនុំនិងគ្មានប្រាជ្ញាគិតដល់ការរាក់ជ្រៅ គួបផ្សំនឹងបានការចាក់ដោតពីមនុស្សចាស់ដែលមានបំណងជាស្រេច គេបានចាត់ទុកឪពុកពៅបញ្ញាថាជាសត្រូវសួរពូជ។
នៅពេលត្រូវម្តាយអូសនាំបង្ខំចូលក្នុងរបងផ្ទះធំនោះ គេបានរើបម្រះហើយរត់ឆ្លងផ្លូវបាត់ស្រមោលរកតាមក៏មិនទាន់។
តាមពិតគេត្រូវបានទទួលដោយអ៊ំប្រុស ហួត ស៊ីវ ដែលតែងតែទំនុកបម្រុង ហើយទទួលជាកូនប្រុសធម៌ជាសម្ងាត់នៅពេលក្រោយមក។

៥ឆ្នាំក្រោយមក...មុនពេលម្តាយគេស្លាប់គេបានជួបប្រឈមនឹង ប៉ែន ពេជ្រ សាជាថ្មីនៅថ្ងៃដែល ប៉ែន ពេជ្រ និងភរិយាដើមទៅជួបម្តាយគេជាចុងក្រោយនៅមន្ទីរពេទ្យ។
ដោយហេតុតែឆេវឆាវក្មេងប្រុសក្នុងវ័យ១៣ឆ្នាំបានគ្រវែងកាតាប បណ្តេញប្តីប្រពន្ធនេះធ្វើឲ្យកាតាបហើរទៅប៉ះនឹងផ្ទាំងកញ្ចក់បោក មកត្រូវជំទាវសក្ខកុសុមារបួសដោយអន្លើ។ កងអង្គរក្សដែលហែហមស្ត្រីអភិជនមិនបានយល់ថាក្មេងប្រុសនេះជា កូនសល់ពីមិត្តជិតដិតរបស់ប្តីគាត់ ក៏ទាញខ្សែក្រវាត់វាយទៅលើគេដោយផ្តាប់ចិត្តលោកជំទាវ។
ដោយសារតែក្មេងប្រុសនោះព្រហើនម្តងជាពីរដងហួសពីអត់ធ្មត់បាន ឧកញ៉ាប៉ែនពេជ្រក៏សង្កត់ចិត្តងាកមុខចេញឲ្យអង្គរក្សភរិយាប្រដៅគេ ខ្លះដឹងអីកូនស្រីពៅរបស់គាត់ដែលនៅរង់ចាំក្នុងឡានក្បែរនោះមិន អាចបោះបង់មនោសញ្ចេតនាចាស់ នាងស្ទុះចុះពីឡានឆ្លងកាត់ក្រុមអង្គរក្សហើយយកខ្នងរងខ្សែ ក្រវាត់នោះជំនួសគេសង្ឃឹមថាឪពុកនឹងព្រមអត់ឱនឲ្យយុត្តនាម្តង ទៀត។
«លោកប៉ា! ឲ្យគេឈប់វ៉ៃគាត់ទៅ»
ហេតុតែនាងជាកូនចុងដែលជាបន្លាក្នុងបេះដូងជាយូរមកហើយ អ្នកជំទាវឃើញថាឱកាសហុចឲ្យក៏រវៃភ្នែកឲ្យសញ្ញាទៅបុរសអង្គរក្ស ជំនិតឲ្យបង្កើនទម្ងន់ដៃបញ្ចេញកំហឹងស្នេហ៍ឲ្យគាត់រហូតដល់សាច់ ខ្នងដ៏ទន់ខ្ចីរបស់ក្មេងស្រីត្រូវរបួសរហែកបែកឈាមក្រហមឆ្អៅក្រោម ភាពតក់ស្លុតរបស់ឪពុក។
ឃើញដូច្នោះទើបគាត់ធ្វើជាឃាត់អង្គរក្សវិញរក្សាភាពត្រឹមត្រូវ ខាងក្រៅសម្បកជាកុលស្ត្រី ជា

អភិជនអ្នកចេះដឹងនោះសាជាថ្មីបន្លំភ្នែកអ្នកផង។
ក្មេងប្រុសទោះខឹងឪពុកនាងតែគេក៏នៅតែមានមនោសញ្ចេតនាជាមួយក្មេង ស្រី គេលូកដៃមកឱបប្រាណដ៏តូចនោះហើយបំបែរមកមើលមុខរបួសដែលរហែកយ៉ាង ដំណំលើស្មា។
«ពៅ?»
«បងយុត្តឈប់មកធ្វើអីផ្ដេសផ្ដាសទៀតទៅ? បងយុត្តធ្វើខុសម្ដងហើយម្ដងទៀត! បងយុត្តឆេវឆាវណាស់! មិនដូចបងយុត្តពីមុនទេ!»នាងបន្ទោសទាំងយំបណ្ដើរដោយការឈឺចាប់។
គេមិនចេញស្ដីតបនឹងពាក្យបន្ទោសរបស់នាង តែកែវភ្នែកគេដែលក្រហមដូចងើកភ្លើងសម្លឹងនាងគឺដិតដាមដោយការឈឺ ចាប់។ គេរង់ចាំឲ្យនាងបញ្ចេញកំហឹងអស់ទើបនិយាយមួយៗទាំងតឹងណែនក្នុង ចិត្ត៖
«ពៅជឿបងឬជឿគាត់! គាត់ជាមនុស្សអាក្រក់! គាត់សម្លាប់ប៉ាបង!»
គ្មានក្មេងស្រីណាដែលមិនកាន់ជើងឪពុកខ្លួនឯងនោះទេ។ កុមារីវ័យ៨ឆ្នាំជូតទឹកភ្នែកក្រោកឃើតៗចេញពីបងប្រុសដែលនាង ធ្លាប់ស្និទ្ធស្នាលរហូតមកហើយនិយាយតបសំណួរគេ៖
«បងយុត្តមានះ! បងយុត្តឆេវឆាវ! បង្កតែរឿង! បងយុត្តនិយាយមួលបង្កាច់អ្នកដទៃ មិនចេះកែខ្លួនទេ!»

រួចនាងរត់ចូលទៅក្នុងឡានចោលក្មេងប្រុសកូនកំព្រាឲ្យនៅឈឺចាប់តែម្នាក់ឯង។
.....ដកអារម្មណ៍ចេញពីអតីតកាល.....យុត្តនាបើកភ្នែកមកវិញ ជាមួយនឹងពាក្យរបស់ស្រីតូចរំពង ពេញត្រចៀកម្ដងហើយម្ដងទៀត...
«បងយុត្តមានះ! បងយុត្តឆេវឆាវ! បង្កតែរឿង! បងយុត្តនិយាយមួលបង្កាច់អ្នកដទៃ មិនចេះកែខ្លួនទេ!»
រំលងពីជាង១០ឆ្នាំ នាងជួបគេសាជាថ្មីនៅ Campu house នាងលែងទន់ភ្លន់ដូចមុន លែងស្និទ្ធស្នាលដូចមុនហើយសម្ដីនាងគឺគ្រោតគ្រាតដូចពេលចុងក្រោយ បង្អស់ដែលនាងរត់ឡើងឡានចោលគេដូច្នោះដែរ៖
«...មនុស្សកុហក! ប៉ាខ្ញុំមិនជឿទេ! ហើយខ្ញុំក៏អត់ជឿដែរ! ឈប់លេងល្បិចស្មោកគ្រោកអញ្ចឹងទៅយុត្តនា!»
នេះជាសម្ដីបដិសេធនិងដៀលត្មះនាយថាជាមនុស្សកុហកមនុស្សមានល្បិច ក្នុងពេលនេះមិនព្រមទទួលស្គាល់ការពិតដែលថាបងប្រុសម្ដាយទីទៃរបស់ នាងជាដើមចមនៃអំពើបោកប្រា

ស់។
....បើកុំតែគេទាញប៉ះអាវនាងបញ្ចេញស្លាកស្នាមលើស្មានោះ....យុត្តនា ភ្លេចបាត់ទៅហើយថាស្ត្រីដ៏គ្រោតគ្រាតគ្មានភាពទន់ភ្លន់នេះកាលពី ប៉ុន្មានឆ្នាំមុនធ្លាប់រងរំពាត់ជំនួសគេ....គេក្តាប់មាត់លើក ទូរសព្ទចុចអក្សរប៉ុន្មានម៉ាត់ផ្ញើទៅនាង....
«ដឹងហើយថាគេងមិនទាន់លក់ទេ!....ស្អែកម៉ោង៦ល្ងាចជួបគ្នា! Campu house ជាន់ទី៦»
ចិត្តគេប្រែជាទន់នៅពេលសរសេរពាក្យប៉ុន្មានម៉ាត់នេះ។
ស្រីដែលគ្មានសម្រស់អ្វីអស្ចារ្យ ម៉េចក៏អាចធ្វើឲ្យយុត្តនាគិតពីនាងក្នុងរាត្រីឯកានេះ...?
«យុត្តនា! ខ្ញុំមិនមែនជាស្រីស្អាតទេ! លោកកុំចាំបាច់ធ្វើអញ្ចឹង»សំឡេងនាងអ្នកនៅចាំបានពិសេសបបូរមាត់នាងដែលត្រូវគ្រប់គ្រងដោយបបូរមាត់អ្នក។
គេសើចចុងមាត់លុបចោលភាពឯកាចិត្តបានមួយខណៈក៏នឹកឃើញសាជាថ្មីដល់សម្តីរបស់រិទ្ធិកាលពីព្រឹក...
«សម្រាប់ខ្ញុំ មនុស្សស្រីឲ្យតែ កតញ្ញូ សុភាពរាបសារ ចេះស្គាល់ចាស់ទុំមិនធ្វើបាបអ្នកណា ខ្ញុំទុកថាជាស្រីស្អាតហើយ!.....ធម្មតា!!!»
«ប្រយ័ត្នក្លាយជាអ្នកស៊ើបចាញ់ស្នេហ៍ចុះចូលនឹងសត្រូវដោយសារលង់ ស្រលាញ់ព្រះនាងម្ចាស់នៃព្រះនគរខ្មាំង! ពេលរិទ្ធិឯងមកប្រាប់ខ្ញុំពីរឿង Johan ខ្ញុំគិតថាមានរឿងពីរ ទីមួយតើឯងពិតជាចង់ឲ្យខ្ញុំបានឱកាសធ្វើបាបចិត្តស្រីនោះ ឬក៏ឯងចង់ជួយនាង!»

គេរវើកភ្នែកគិតម្នាក់ឯង....បុរសសង្ហាហើយនឹងនដូចរិទ្ធិ ទំនងជាគ្មានឧបសគ្គទេក្នុងការបានបេះដូងអ្នកនាងតូចផ្ទះប៉ែនពេជ្រ  តែការពិតចំពោះមុខគឺយប់នោះភាគីខាងប្រុសជាអ្នកឆ្លេឆ្លាខាងក្រោមបើកឡានចុះឡើងស្ទើរសឹកផ្លូវចាំដំណើរនាង ទាំងគេដឹងចរិតយុត្តនាហើយថាអ្នកគ្មានថ្ងៃធ្វើបាបចាប់បង្ខំ មនុស្សស្រីដែលគេមិនស្ម័គ្រចិត្តនោះឡើយ។
«ចុះនាងមានច្រឡំទៅលង់ស្រលាញ់អាជនបង្កប់នោះវិញទេស្រីល្ងង់ អើយ!!?»យុត្តនាគិតស្ងាត់ៗក្នុងចិត្តល្មមពេលសូរ SMS មួយលាន់មកវិញ។
គេមិនទាន់លូកដៃទៅលើកទេ ដោយគ្រាន់តែដៀងភ្នែកទៅមើល។
ទោះយ៉ាងណាគេដឹងថាគឺពៅបញ្ញា....។
អ្នកប្រុសទីមួយរបស់គ្រួសារអគ្គទេសាភិបាលលូកដៃទៅចុចទូរសព្ទលើតុ មើលទាំងមិនខ្ជីលើកផ្ទុយទៅនឹងសន្ទុះចិត្តអ្នកដែលចង់ដឹង យ៉ាងអន្ទះសាថានាងសរសេរមកវិញដូចម្តេច។

«ខ្ញុំមានធុរៈនៅខេត្តកណ្ដាល! អាចលើកពេលសិនបានទេ?»
យុត្តានាដៃម្ខាងដាក់ស្មើនឹងបបូរមាត់ខ្លួនហាក់មានចេតនាបិទបាំងស្នាមញញឹមដៃម្ខាងទៀតចុចអក្សរតបទៅនាង៖
«ទៅខេត្តកណ្ដាលធ្វើអី?»
សំណួរអ្នកសរសេរគឺខ្លី តែសម្រាប់អ្នកទទួលគឺនាងមានអារម្មណ៍ថាឃ្លារបស់គេមួយណាក៏ដូចជាផ្ដាច់ការផុតលេខដែរ។
«មានការទៅជួបចៅក្រមម្នាក់!»បើមិនជំពាក់នាយ នាងយល់ថាខ្លួនឯងមិនចាំបាច់ឆ្លើយសំណួរអស់នេះ។
«ចៅក្រមឈ្មោះអី?»
«លោកមិនស្គាល់ទេ!»
«អស្ចារ្យណាស់ហើយ! ស្គាល់សុទ្ធតែចៅក្រម! Cancel គេទៅ! ប្រាប់ទៅថា នាងជាប់មកជួបខ្ញុំ!»
នាងលែងឆ្លើយតែម្ដង គឺនាងហួសចិត្តនឹងចរិតមិនដឹងខុសត្រូវនេះ។ ចំណែកភាគីខាងប្រុសគេចាំយូរពេកក៏លង់លក់ទៅជាមួយស្នាមញញឹមជាប់ បបូរមាត់ដែលបានធ្វើឲ្យស្រីតូចខ្វល់ខ្វាយចិត្តពេញមួយរាត្រី។

## ១០

«លោកជំទាវកិរិយាស្មើមេឃ សក្ខកុសុមា»

...ប្រសិនបើជំទាវសក្ខកុសុមាមិនមែនជាស្រីស្អាតគឺមិនពិតឡើយ...ព្រោះពុំនោះទេ ម្ដេចក៏សង្សារចាស់របស់គាត់មិនដាច់ចិត្តលើកផ្កាស្លាទៅដណ្ដឹង ស្រីណាផ្សេងធ្វើជាភរិយាក្នុងរវាងពេលជាងម្ភៃឆ្នាំមកនេះ?
..សូម្បីតែពេលនេះ មិនមានពិធីអ្វីធំដុំក៏លោកជំទាវប្រដាប់ដោយសំលៀកបំពាក់រចនាពីសូត្រស្ដើងពណ៌ខ្លីមខ្នុរលេចសាច់សដូចពងមាន់ បកបង្អួតភ្នែកអគ្គទេសាភិបាល ហួតស៊ីវដែរ។

...លោកអគ្គទេសាភិបាលវ័យហាប្លាយចេញចូលផ្ទះអតីតភរិយាឧកញ៉ាប៉ែនពេជ្រសឹងក្លាយទម្លាប់សម្រាប់អ្នកបម្រើប្រុសស្រីទៅហើយ។
តែថ្ងៃនេះទំនងជារឿងអ្វីមួយដែលធ្វើឲ្យលោកជំទាវមិនត្រូវចិត្តទេបានជាកិច្ចសន្ទនារបស់អ្នក

ទាំងទ្វេប្រែទៅជាតឹងតែង៖
«អត់ទេ! ខ្ញុំមិនឲ្យកូនអមរាទៅផ្សារសាច់ឈាមអីជាមួយកូនអ្នកគ្មានពូជ ត្រកូលនោះទេ! ឪពុកម្ដាយគេជាអ្នកណា? គ្រាន់តែជាអ្នករស់នៅប្លុកក្រីក្រជាន់កប់អាកាស! កាលនៅរស់ក៏គ្មានទេពកោសល្យស្នាដៃអីគួរឲ្យលេចធ្លោ! ពេលនេះឪពុកក៏គ្មានម្ដាយក៏អត់ លោកខំផ្ចុងផ្ដើមយកគេមកធ្វើជាកូនប្រុសធម៌តែគេនៅតែគ្មានកំណើត មុជមិនជ្រៅទៅមិនឆ្ងាយ! រៀនក៏មិនសមថារៀន ធ្វើការក៏មិនឃើញអីដុំកំភួន ដើរលេងហ៊ឺហារ រស់នៅ Apartment ដូរស្រីចុះឡើង! និយាយខ្លីអមរាមិនសមជាមួយពួកមនុស្សប្រុសប្រភេទហ្នឹងទេ! បើថាចង់រកប្រពន្ធឲ្យកូនប្រុសលោកណាស់ ទៅរកកន្លែងផ្សេងដែលសមជាងនេះទៅ មិនមែនកូនស្រីផ្ទះនេះទេ!»

ពេលជំទាវរំលឹកពីរឿងពូជត្រកូលដែលថាឪពុកម្ដាយយុត្តនាជាអ្នក ក្រគ្មានកេរ្តិ៍គ្មានឈ្មោះ ធ្វើឲ្យបុរសចំណាស់ ហួត ស៊ីវ នឹកឃើញភ្លាមដល់អតីតកាលដ៏ឈឺចាប់របស់ខ្លួនដែលបានប្រាស់ព្រាត់ពី សង្សារសំណព្វក៏ដោយសារតែការរើសអើងរឿងពូជត្រកូលនេះ។ ទោះបីយុត្តនាមិនមែនជាកូនបង្កើត ហើយគាត់យកគេមកចិញ្ចឹមក៏ដើម្បីប្រើប្រាស់ចិត្តឆេវឆាវរបស់គេ ប្រឆាំងនិង ប៉ែន ពេជ្រ ប៉ុន្តែអមរាគឺជាកូនស្រីបង្កើតរបស់គាត់ប្រសិនបើគាត់មិនមើល ឃើញចំណុចពិសេសរបស់កំលោះកំព្រានោះគាត់ក៏មិនប្រថុយយកវាសនាកូន ស្រីទៅលេងសើចដែរ។គាប់ជួនពេលនេះលោកជំទាវអតីតសង្សារលើករឿងពូជ ត្រកូលមកជាលេស គាត់ក៏កើតក្ដៅស្លឹកត្រចៀកនិយាយខឹងវិញ៖
«ចុះបើកូនប្រុសខ្ញុំ ជាអគ្គទេសាភិបាលថ្មីនៅថ្ងៃស្អែក?»
ជំទាវដ៏ស្រស់ផូរផង់ក្មេងជាងវ័យងាកភ្លែតមកសម្លឹងមុខបុរសដែល ស្រលាញ់នាងពេញមួយជីវិតមកនេះ។ ហួត ស៊ីវ ញាក់ចិញ្ចើមជាសញ្ញាថាគាត់មិននិយាយលេងទេធ្វើឲ្យលោកជំទាវភ្លាត់ មាត់តិចៗដោយភិតភ័យ៖
«លោកថាម៉េចស៊ីវ?»
«លោកជំទាវស្ដាប់មិនច្រឡំទេ!! គឺតំណែងអគ្គទេសាភិបាលរបស់ខ្ញុំនឹងផ្ទេរឲ្យគេ! យុត្តនាកូនប្រុសច្បងរបស់ខ្ញុំ!»
សម្រាប់ព័ត៌មាននៃការប្រគល់តំណែងខ្ពស់បង្អស់របស់ស្ថាប័ន ហិរញ្ញវត្ថុល្បីផុតគេ ដែលមានតម្លៃប៉ាន់ស្មានរាប់សិបលានដុល្លារអាមេរិកធ្វើឲ្យលោកជំទាវ មិនអាចទប់ចិត្តមិនបន្ថែមមកនូវសំណួរដែលគាត់មិនគួរសួរនោះទេ៖

«ចុះកូនប្រាថ្នា?....ចុះកូនប្រុសខ្ញុំ?»
ហួត ស៊ីវ ស្រលាញ់ ប៉ែន ពេជ្រប្រាថ្នា ស្មើជីវិត។

បុរសវ័យ ក្មេងដែលទន់ភ្លន់ខាងក្រៅក្រឡេចក្រឡុចខាងក្នុងនិងមានភាសា ផ្អែមល្ហែមពូកែ បំភ័ន្តភ្នែកអ្នកផងជាសុភាពបុរសបានយ៉ាងល្អនោះគឺ មានលក្ខណៈសម្បត្តិដូចគ្នាទាំងស្រុង ទៅនឹងឪពុកបង្កើតរបស់គេដែល គ្មានសំណាងបានហៅម្តាយគេថាជាប្រពន្ធនោះ។ កូនបង្កើតនិងកូនចិញ្ចឹមទូទាត់គ្នា១០០ដងក៏នៅតែមិនអាចស្មើបាន ដែរ ប៉ុន្តែលើកនេះ ហួត ស៊ីវ ពិតជាមានមូលហេតុក្នុងការបង្វែរតួនាទីកំពូលនេះឲ្យទៅកូនធម៌ ច្បង។ ជួនជាត្រូវជំទាវ បញ្ឈឺដោយពាក្យពូជពង្សអីទៀត ក្តីមានៈរឹតតែឆេះមកសន្ធៅ។
គាត់និយាយឌឺដងវិញ៖
«ប្រាថ្នាមានប៉ាគេជាពូជអ្នកច្បាប់ មានអ្នកម៉ាក់គេជាជំទាវសែស្រឡាយហ្លួងទៅហើយ! គេចាំបាច់អីត្រូវការតំណែងពីមនុស្សគ្មានពូជគ្មានត្រកូលដូច ខ្ញុំ? ឲ្យគេទៅរកប៉ាគេឧកញ៉ា ប៉ែន ពេជ្រ នោះទៅ!»
លោកជំទាវដឹងថាគាត់និយាយដៀមដាមព្រោះច្រណែននឹងបុរសនោះ។ វាជាចិត្តច្រណែន ប្រចណ្ឌដែលជិតម្ភៃឆ្នាំហើយនៅតែមិនអាចរំងាប់ បាន គឺមានន័យថា ក៏គ្មានអ្នកណាក្នុង លោកនេះអាចពន្លត់បានដែរគឺមានតែអ្នកដែល បង្កាត់វាត្រូវប្រឈមពន្លត់វាដោយខ្លួនឯង។ ជំទាវឈ្ងោកមុខប្តូរឥរិយាបថ គាត់ស្រដីរអាក់រអួល៖
«លោកកុំភ្លេចថា កូនប្រាថ្នាទើបជាកូនប្រុសបង្កើតរបស់លោក! លោកចងគំនុំអីចងទៅ កុំ រាលដាលដល់កូនខ្ញុំ! អមរានិងប្រាថ្នាពីរនាក់នេះទើបជាសាច់ឈាមរបស់លោកពីរនាក់គេ ទើប សមថាទទួលបានអ្វីៗទាំងអស់ដែលជារបស់លោកមិនមែនក្មេងប្រុស ខ្វាត់ព្រាត់ម្នាក់ នោះទេណ៎ា!»
«អញ្ចឹងនាងប្រាប់ឲ្យកូនភ្លោះរបស់នាងប្តូរត្រកូលមកដាក់ត្រកូល ហួតទៅកុសុមា! អ្វីគ្រប់ យ៉ាងខ្ញុំផ្ទេរឲ្យពីរនាក់គេ!» ហួត ស៊ីវ និយាយបញ្ឈឺទាំងញញឹមស្មើ។

លោកអគ្គទេសាភិបាលដឹងហើយថាស្ត្រីត្រកូលខ្ពស់ម្នាក់នេះកាលពី ម្ភៃឆ្នាំមុនសុខចិត្ត លះបង់សង្សារទៅរៀបការតាមឪពុកម្តាយជាមួយ ប្រុសផ្សេងទាំងខ្លួនមានកូនភ្លោះក្នុងផ្ទៃ ក៏ ព្រោះតែនាងមិនអាចលះបង់កេរ្តិ៍ឈ្មោះជាមនុស្សជាន់ខ្ពស់របស់នាង ដើម្បីស្នេហាបាន។ រហូតដល់ពេលនេះទៀត ទោះបីនាងបានលែងលះស្វាមីទៅហើយក៏ដោយក៏នាងនៅតែមិន

អាចឲ្យមហាជន ដឹងការពិត កូនស្រីប្រុសពីរនាក់នោះជាកូនឥតខាន់ស្លាដែរ។
ក្នុងខណៈដែលលោកជំទាវនៅទ្រឹង ហួតស៊ីវផ្ទុះសំណើចសើចក្អាកក្អាយៈ
«ខ្ញុំដឹងហើយកុសុមា! នាងមិនបាច់និយាយក៏ខ្ញុំដឹង! នាងសុខចិត្តកុហកមនុស្សគ្រប់គ្នាកុហកខ្លួនឯងមួយជីវិតនេះទៀតក៏ នាងនៅតែកុហកបាន! ឲ្យតែមានឈ្មោះថាមនុស្សអភិជនមនុស្សឋានៈខ្ពស់កប់ពពក! សូម្បីខ្ចីត្រកូលអ្នកផ្សេងមកឲ្យកូនដាក់ក៏នាងទ្រាំធ្វើ! អញ្ចឹងនាងកុំស្ដាយអីទ្រព្យសម្បត្តិអស់នេះ! អ្នកណាប្រើត្រកូលខ្ញុំ ខ្ញុំឲ្យទៅអ្នកនោះ! បើនាងចង់បាន នាងឲ្យកូនស្រីរៀបការជាមួយយុត្តនាទៅវាចប់រឿងទៅហើយ!»
ហៀបនឹងក្រោកដើរចេញគាត់នៅឱនមកខ្សឹបបញ្ឈឺបន្ថែមៈ
«ធ្វើអញ្ចឹងទើបវាមិនខូចឈ្មោះហើយក៏មិនបែកទ្រព្យទៀតលោកជំទាវ!»
អគ្គទេសាភិបាលបោះជំហានចេញទៅទាំងទឹកមុខឈឺចាប់ ។
ប្រការដែលគាត់យល់ថាបានខុសធ្ងន់បំផុតក្នុងជីវិតគឺបានស្រលាញ់ ប៉ះស្រីម្នាក់ដែលគ្រួសារនាងបានមាក់ងាយគ្រួសារគាត់មិនឲ្យតម្លៃ គាត់ ចំណែកឯទីពីរគឺមិត្តម្នាក់របស់គាត់បានមករៀបការយកសង្សារគាត់ ទៅធ្វើជាប្រពន្ធ ហើយទីបីគឺមនុស្សដែលគាត់គោរពបំផុតបានឲ្យគម្រោងការចុងក្រោយមុន ពេលគេបិទភ្នែកលាចាកលោកនេះទៅឲ្យអ្នកផ្សេង ដែលតាមពិតគ្មានទេពកោសល្យរកស៊ីលើសគាត់សោះ។

អគ្គទេសាភិបាល កំលោះចាស់ចាកពីបន្ទប់សាឡុងមកដល់ទ្វារខាងក្រៅគាត់ភ្ញាក់ក្រញាងដូចត្រូវគេជះទឹកចំកណ្ដាលមុខ។
អ្នកនាងធំនៃផ្ទះជំទាវកុសុមា ប៉ែន ពេជ្រអមរា ទាំងសាច់ទាំងឈាមកំពុងឈរទ្រឹងនៅចំកណ្ដាលទ្វារ។ ទឹកភ្នែកពីរដំណក់នៅលើថ្ពាល់នាង នឹងកែវភ្នែកល្ហល្ហេវរបស់នាងដែលមិនសម្លឹងលោកឲ្យចំដូចពេលមុនៗ គឺបញ្ជាក់ស្រេចហើយថា នាងបានឮការសន្ទនានេះគ្រប់យ៉ាង រួមទាំងប្រវត្តិជាកូនឥតខាន់ស្លារបស់នាងផងដែរ។
ហួត ស៊ីវ លាន់មាត់តិចៗៈ
«អមរា?»
ការលាន់មាត់របស់គាត់បានធ្វើឲ្យលោកជំទាវដែលអង្គុយបែរខ្នងភ្ញាក់ ក្រញាង ហើយស្ទុះក្រោកចេញមកទាំងតក់ស្លុត។ គាត់ប្រឈមនឹងបុត្រីដែលសម្លឹងគាត់ថ្លៃបន្ទាប់មកនាងយំសស្រាក់ហើយដកក្រសែភ្នែកចេញពីម្ដាយមុនពេលរត់ចេញទៅ។

ហួត ស៊ីវ សម្លឹងទៅស្ត្រីម្ចាស់ផ្ទះ។ គាត់ឃើញជំទាវទន់ជើងអង្គុយប៉ុកទៅលើកៅអីក្បែរនោះដោយទឹកមុខស្លេកស្លាំង។
ការពិតដ៏អាស្រូវដែលខំលាក់លៀមអស់ពេលវេលាដ៏យូរ បែរជាត្រូវបានបន្ថែមចំនួនអ្នកដឹងឮនៅថ្ងៃនេះ ពិសេសអ្នកនោះគឺសាមីខ្លួនផ្ទាល់ទៀត.....

១១

«ល្បិចកល ហួត ស៊ីវ»

.....ត្រលប់មកពីផ្ទះអតីតសង្សារ... លោកអគ្គទេសាភិបាលក៏មិនស្រួលចិត្តប៉ុន្មានដែរ ។ កាលដែលកូនស្រីបង្កើតស្តាប់ឮប្រវត្តិអាស្រូវរបស់នាងប្រាកដណាស់ថា នាងមុខតែមានសតិអារម្មណ៍ផ្លូវចិត្តហើយទទួលយកភ្លាមៗមិនបានឡើយ។
គាត់អង្គុយលើកៅអីធ្វើការភ្នែកសញ្ជឹងគិតវែងឆ្ងាយចោលពេលបាយទឹកធ្វើឲ្យលេខាប៉េងឆ្លេឆ្លារកមធ្យោបាយដោះទុក្ខចៅហ្វាយ។
«លោកអគ្គ! ឪពុករើសប្តីឲ្យកូនជារឿងធម្មតា! លោកកុំពិបាកចិត្តគិតអីច្រើន! មិនយូរមិនឆាប់អ្នកនាងអមរាច្បាស់ជាយល់ហើយព្រមធ្វើតាមលោក មិនខាន! ឧកញ៉ាប៉ែន ពេជ្រ មានតែសម្បកខ្លួនល្អតែឈ្មោះតែសម័យនេះ មនុស្សគេត្រូវការលុយជាងអ្វីៗទាំងអស់! ឪពុកណាមានលុយ កូនៗនឹងស្តាប់ឪពុកនោះជាង!»
មានតែលេខាប៉េងទេដែលនិយាយអ្វីក៏ត្រូវចិត្តស៊ីវ ព្រោះគាត់ដឹងថាចៅហ្វាយខ្លួនជាមនុស្សមោទនភាពផុតលេខហើយចូលចិត្ត ឲ្យគេធ្វើតាមគំនិតខ្លួន។ តែលើកនេះសម្តីរបស់គាត់មិនបានធ្វើឲ្យធូរស្រាលទឹកមុខចៅហ្វាយឡើយ ។
ហួត ស៊ីវ និយាយស្រាលៗមកវិញ៖
«អមរាជាសាច់ឈាមខ្ញុំ!! រឿងឈាមរត់រកឈាមជារឿងធម្មតា! តែដែលសំខាន់គឺខាងយុត្តនាវិញ! »
«លោកអគ្គខ្លាចអ្នកប្រុសធំមិនព្រមនឹងមង្គលការនេះ?»
ហួត ស៊ីវមិនមាត់។
ទោះបីច្រើនឆ្នាំមកនេះគេដើរតួជាឪពុកចិញ្ចឹមល្អចលោក់ មានកូនប្រុសដល់ទៅបីនាក់ម្នាក់ជាកូនបង្កើត ហើយពីរនាក់ទៀតជាគ្រាប់អុកប្រយុទ្ធនៃគំនុំអតីតកាល ប៉ុន្តែគេប្រាកដចិត្តណាស់ថា រិទ្ធិនិងយុត្តនាគឺជាកូនកតញ្ញូគ្មានថ្ងៃធ្វើឲ្យខ្លួនលំបាក ឡើយ។ ទោះបីយុត្តនាមើលទៅជា

មនុស្សសេរីនិយមមិនចូលចិត្តការគាបសង្កត់ ខុសប្លែកពីរិទ្ធិដែលស្រគត់ស្រគំលុះដំបូន្មានឲ្យធ្វើអ្វីក៏មិន ប្រកែក តែហួត ស៊ីវ ជឿថាខ្លួនមានមធ្យោបាយយកបេះដូងយុត្តនាមកឲ្យកូនស្រីបង្កើតបាន។

«យុត្តនា! ក្មេងនេះមើលពីក្រៅឆេវឆាវ តែមនោសញ្ចេតនាខាងក្នុងពិតគឺទន់! ចរិតឪពុកវាគឺផ្ញើទុកនៅវាទាំងអស់! ជំទាវនោះមិនចេះមើលមនុស្ស! កាលពីម្ល៉េឆ្នាំមុនចោលអង្ករយកអង្កាមឥឡូវសក់ពីរពណ៌នៅតែមិនចោលចរិតមើលមនុស្សសម្បកក្រៅដដែល! ក្នុងចំណោមក្មេងប្រុសបីនាក់នេះ កូនច្បងខ្ញុំជាកាំបិតដែលមុតជាងគេ!»

គាត់សើចស្រាលៗពេលនិយាយដល់ចំណុចនេះ។ លេខាប៉េងនិយាយតិចៗវិញ៖

«តែរឿងផ្លូវចិត្ត ....?»

ហួត ស៊ីវ ដៀងភ្នែកសម្លឹងគេ។ ប៉េងយល់ចិត្តចៅហ្វាយគេឱនមកខ្សឹបក្បែរត្រចៀក៖

«មួយរយៈនេះ អ្នកប្រុសឡើងទៅផ្ទះចាស់នោះ! ទៅម្តងៗសំងំហូបបីយ៉េរមួយយប់ទល់ភ្លឺតែម្នាក់ឯង!»

«មានអីទាក់ទងគ្នានឹងរឿងមង្គលការជាមួយអមរា!?»

«គឺវាបង្ហាញថា អ្នកប្រុសនៅនឹកឪពុក....ហើយ........!»

«ហើយយ៉ាងម៉េច? កុំរៀននិយាយបញ្ចេញដើមបង្កប់ចុងអញ្ចឹងរ៉ី?»

«បាទគឺ....កាល....កាលពីនៅរស់ ឪពុកគេធ្លាប់ចង់ឲ្យគេបានកូនស្រីប៉ែន ពេជ្រ!»

«ចុះឥឡូវ បើគេរៀបការក្នុងនាមការជាមួយកូនអាពេជ្រហ្នឹងហើយ!»

«តែ...ខ្លាចថាក្នុងបេះដូងអ្នកប្រុស មិនមែនកូនស្រី ប៉ែន ពេជ្រ ដែលនៅផ្ទះធំនោះទេលោកអគ្គ!»

ហួត ស៊ីវ បង្ហាញភាពមិនពេញចិត្តតាមពន្លឺភ្នែក។ គេធ្វើមមីរិះគិត៖

«ក្មេងស្រីសម្បុរខ្មៅនោះហ្អី?»

ប៉េងលេបទឹកមាត់លែងនិយាយថែមថយ។

ដូចគេគិតមែន ហួត ស៊ីវ មិនបញ្ឈប់សម្តីត្រឹមតែសំណួរនោះទេ គាត់និយាយបន្ថែមជាបន្តបន្ទាប់៖

«គ្មានកូនប្រុសយើងណាម្នាក់ត្រូវទៅទាក់ទាមជាមួយកូនស្រីអាពេជ្រ ណាម្នាក់ទេ! ទាំងកូនម្តាយដើមឬម្តាយចុង! គឺឲ្យតែឈាមវាជាសត្រូវរបស់យើង!»

រឿងចាក់ដោតជារឿងដ៏ថ្មីករបស់លេខាប៉េងស្រាប់ហើយ។ បុរសចិនសំគមលូកមាត់មកបន្ថែមល្បោយៈ
«អញ្ចឹងទាល់តែលោកអគ្គរៀបជើងព្រួលទប់ទឹកឲ្យបានមុនពេលបាក់ទំនប់!»
ហួតស៊ីវលើកដៃឲ្យសញ្ញាៈ
«ធ្វើអីធ្វើទៅ! ធ្វើយ៉ាងណាឲ្យកូនប្រុសខ្ញុំយុត្តនាជាមួយក្មេងស្រីនោះមើលមុខ គ្នាមិនត្រង់ដល់ថ្ងៃស្លាប់! ខ្ញុំចង់ដឹងថា អានិស្សយ៍ស្និតល្អតរបស់ឪៗវាសងខាង អាចយកឈ្នះគម្រោងការខ្ញុំរបៀបម៉េចបាន?»
គាត់ដៀងភ្នែកដែលពោរពេញដោយអំនួតសម្លឹងទៅលេខាកំហូច ធ្វើឲ្យជននោះសើចជាសញ្ញារីករាយក្នុងផ្លូវដ៏អាក្រក់របស់ខ្លួន។
.....ដូច្នេះហើយបានជាយប់នោះ គេឃើញម៉ូតូធំពីរបីគ្រឿងសំងំចាំនៅក្លឹបរាត្រីជាស្រេច។ ម៉ោងមួយអធ្រាត្រពេលដែលយុត្តនាដើរតម្រង់មករករថយន្ត អ្នកទទួលអារម្មណ៍ហាក់ត្រូវបានឃ្លាំមើល។
ទោះយ៉ាងណាបុរសនេះនៅតែបើករថយន្តធ្វើហីគ្រាន់តែបង្កើនល្បឿនបោះពួយ ខុសគោលដៅម្តងត្រង់ណេះម្តងទៅនោះឲ្យក្រុមអ្នកតាមអមដំណើរ វិលក្បុង។
«នាំគ្នាចាំនៅទីនោះហើយ! ខ្ញុំនាំពួកវាទៅ!»
គេទម្លាក់ទូរសព្ទចុះ ហើយសម្លឹងមើលម៉ូតូបួនគ្រឿងនោះតាមកញ្ចក់ផ្នែកខាងមុខរួចបន្ថែមល្បឿនរថយន្ត។ ដូចការគិតបេះបិទក្រុមអ្នកតាមក៏បន្ថែមល្បឿនបរដេញតាមយកឈ្នះដៃផ្អើលអស់អ្នកលក់ដូរចិញ្ចើមថ្នល់នានា ។
គេគិតពីដេញតាមអ្នកប្រុសទីមួយដូចស្រមោចតាមរោមស្ករ តែគេមិនគិតដល់ទេថាស្ករនោះអាចជានុយចាប់ត្រី....អញ្ចឹងហើយនៅ មិនដល់ពីរនាទីផង...ម៉ូតូទាំងបួនបានមកដល់កែងផ្លូវតូចដែលមានម៉ូតូ ច្រើនទៀតនៅរាយជាសំណាញ់រង់ចាំពួកគេជាស្រេច....គេរកបកក្រោយដែរតែ ទៅមិនរួចព្រោះថា អន្ទាក់បើបានជាដាក់ហើយ គឺទាល់តែជាប់សត្វទើបស្រាយ....
.......

«សួរចម្លើយពួកវាហើយអ្នកប្រុស!»
សំឡេងកូនចៅរាយការណ៍ប្រាប់អ្នកប្រុសមេកោយ ដែលកំពុងអង្គុយរង់ចាំព័ត៌មានកណ្តាលយប់ស្ងាត់លើផ្ទះចាស់ជាន់ទីបួន។

«វាប្រុងធ្វើអី! ហើយអ្នកណាប្រើម៉ោ!»
«ខាងហ្នឹងមែនបង! ដំបូងវាអត់ព្រមនិយាយទេ តែនាមប័ណ្ណ ប៉ែន ពេជ្រប្រាថ្នា ក្នុងហោប៉ៅអាវវា! វាអស់ប្រកែកបានបណ្ដោយ! »
យុត្តនាសើចក្នុងបំពង់ក៖
«ស្អីគេ? អាកំសាកហ្នឹង ដែលឯណាប្រមាត់ធំម្ល៉ឹងនោះ!?»
«ដំបូងអត់ជឿដែរតែថា! ម្សិលម៉្ងៃមួយប្អូនស្រីគេទៅជួប! គេចូលនិយាយគ្នាយូរណាស់! ប្រហែលជាវិធីបំបិទមាត់ហើយអ្នកប្រុស!»
«បំបិទមាត់ស្អី?»
«អ្នកប្រុសដឹងរឿងគ្រួសារគេច្រើនពេក! ចាប់អាចូហាន! គំរាមប្អូនស្រីគេឲ្យទៅជួប! គេមិនចង់ឲ្យមានរឿងវែងឆ្ងាយ!»
«មិនសមថាពីរនាក់បងប្អូននោះត្រូវគ្នាទេវ៉ី!»យុត្តនានិយាយទាំង ចាប់ផ្ដើមរំពើតកំហឹងក្នុងចិត្ត។ គេគ្រាន់តែដោះសាកុហកចិត្តខ្លួនឯងប៉ុណ្ណោះ តាមពិតគេជឿដល់សេចក្ដីរាយការណ៍នេះ១០០ភាគរយព្រោះទើបតែយប់មិញ ឆាឆៅនាង ហើយស្រីនោះស្រលាញ់ឪពុកយ៉ាងនេះ បើនាងមិនចាត់ការបំបិទមាត់នាយ ដើម្បីបញ្ចប់រឿងទើបចម្លែក។
ពេលគេកំពុងធ្វើមុខស្មើលាក់អារម្មណ៍ អ្នករាយការណ៍ផ្ដល់គំនិតបន្ថែម៖
«ប៉ែន ពេជ្រប្រាថ្នា ដេកមិនលក់បក់មិនល្ហើយទេ ព្រោះថាអាចូហានក្នុងដៃយើង! បើវាព្រមទុកអ្នកប្រុស មានតែវាព្រមដេកមិនលក់អញ្ជឹងរហូតទៅ!»
«ឯងស្មានឬក៏អ្នកណានិយាយ?» គេធ្វើជាសួរទាំងលើកម្រាមដៃមកដាក់ក្បែរបបូរមាត់ឯភ្នែកសញ្ជឹងគិត។
«វាយវាឈឺសាច់វាសារភាពចេញមកអស់!!»
យុត្តនានៅតែព្យាយាមទាញសាច់រឿងកុំឲ្យពាក់ព័ន្ធនឹងនាង៖
«អាចថាអាបងប្រុសគម្រក់នោះវាធ្វើមានអីទាក់ទងនិងពៅបញ្ញា!»
«អត់ទេទាន! ច្បាស់ការណាស់! វាសារភាពថាបងប្រុសគេធ្វើរឿងនេះ ព្រោះខឹងដែលយប់មិញអ្នកប្រុសទូរសព្ទទៅឆាឆៅប្អូនគេ!»
«រឿងប៉ុណ្ណឹងនាងមានកន្លែងត្រូវប្ដឹងទៀតពៅបញ្ញា?»
គេគិតស្ងាត់ក្នុងចិត្តតែបបូរមាត់ញញឹម។ កូនចៅបរិយាយមកបន្ថែម៖
«អ្នកផ្ទះនោះមិនដឹងថាអ្នកប្រុសជាកូនធម៌អ្នកណា ស្មានតែថាម្នាក់ឯងគ្មានខ្នងគ្មានគ្នាក៏រកផ្លូវ

បញ្ចប់រឿងរបៀប នេះ! គិតសងវិញយ៉ាងម៉េចដែរបង? បញ្ជូនអាបួននាក់នោះទៅប៉ូលិស បញ្ជូនអាបារាំងចូហាននោះដែរឲ្យកាសែតសរសេររឿងបងប្រុសរបស់មេធាវី ល្បីលេងមួយក្បាច់បោកលុយឪខ្លួនឯងឲ្យរបើកមេឃម្ដងមើល៍!»

យុត្តនានៅស្ងៀមមិនមាត់ កូនចៅម្នាក់ទៀតនិយាយបន្ថែម៖
«ស្រីនោះមានពិសមែន! បើកុំតែបានអ្នកប្រុសជួយរកប្រភពស្ពានថាបានលុយមកវិញហើយ នាំឪ កូនដេកលក់ស្រួលអញ្ចឹង!? នៅមិននៅចង់បំបាត់ដានទៀត សាហាវហួស! អួតខ្លួនសុទ្ធតែត្រឹមត្រូវ សុទ្ធតែអ្នកច្បាប់! និយាយទៅមនុស្សស្រីពិបាកទុកចិត្តមែន ពិសេសអាពួកធ្វើឫកល្អខាងក្រៅថ្លៃថ្នូរអីនេះ ច្រើនគ្នាហើយ! ចាត់ការយ៉ាងម៉េចវិញអ្នកប្រុស?»
យុត្តនាមិនមាត់ក៏គិតពីឈ្មោកចុចទូរសព្ទដៃលេង តែពួកដៃជើងលបមើលមុខគ្នាដោយដឹងថាការងារបានជោគជ័យ។

https://www.facebook.com/306238139571077/videos/231091010805965